ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

១៩-៦-២០០៥	-ព្រះរាជក្រម នស/រកម/០៦០៥/០១៧ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ	៣៩៧៥
១៩-៦-២០០៥	-ព្រះរាជក្រម នស/រកម/០៦០៥/០១៨ ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨៨ និង មាត្រា ១១១ ថ្មី នៃរដ្ឋធម្មនុញ្ញ	៣៩៨២
២០-៦-២០០៥	-ព្រះរាជក្រម នស/រកម/០៦០៥/០២០ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា	៣៩៨៥
៣០-៦-២០០៥	-ព្រះរាជក្រម នស/រកម/០៦០៥/០២១ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ	៣៩៩៧

២_ព្រះរាជក្រឹត្យ

១៩-៦-២០០៥	-ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨១ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **សុខ អាន** នូវ **គ្រឿងឥស្សរិយយស ជាតូបការ**	៤០២៣
១៩-៦-២០០៥	-ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨២ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម នាយឧត្តមសេនីយ៍ **ខៀវ សាញ់** នូវ **គ្រឿងឥស្សរិយយស ជាតូបការ**	៤០២៤
២៣-៦-២០០៥	-ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៤ ស្តីពីការតែងតាំងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៣ រូប	៤០២៥
២៣-៦-២០០៥	-ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៥ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ និងសមាជិក នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ០៩ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ	៤០២៦
២៤-៦-២០០៥	-ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៦ ស្តីពីការតែងតាំងឯកឧត្តម **គង់ សុភី** ជាអគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានឋានៈស្មើ **អគ្គនាយក** ជំនួស ឯកឧត្តម **ឆេត ដារ៉ុង**	៤០២៨

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៧ ស្តីពីការដាក់មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌ និងមុខតំណែងមុខងារសាធារណៈដោយនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល ជូនមន្ត្រីរាជការក្រសួងព្រះបរមរាជវាំង ចំនួន ០៣ រូប ៤០២៩

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៨ ស្តីពីការតែងតាំងឯកឧត្តម **អៀត សុខ** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៤០៣០

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៨៩ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ ចំពោះសពឯកឧត្តម **ខូន ផនស៊ីផុន** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៤០៣១

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩០ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុំ ម៉ុនឡឿន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ៤០៣២

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩១ ស្តីពីការតែងតាំង :

១-ឯកឧត្តម **ហេង ពៅ**

២-លោកជំទាវ **ខួត ធីតា** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៤០៣៣

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩២ ស្តីពីការតម្លើងឋានន្តរស័ក្តិឧត្តមមន្ត្រី ពីថ្នាក់លេខ ២ ទៅថ្នាក់លេខ ១ ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពឯកឧត្តម **ខូន ផនស៊ីផុន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ៤០៣៤

២៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៣ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុំ ម៉ាន្ធិន** ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួសលោកជំទាវ **កែវ ម៉ុនធួក** ៤០៣៥

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៤ ស្តីពីការតែងតាំងឯកឧត្តម **ភូច វណ្ណៈ** ជាទីប្រឹក្សាអមរាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ **រដ្ឋលេខាធិការ**បន្ថែមលើមុខងារបច្ចុប្បន្ន ៤០៣៦

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៥ ស្តីពីការតែងតាំងឯកឧត្តម **ឡូច សុវ៉ាង** ជាទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៤០៣៧

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៦ ស្តីពីការតែងតាំងសមាសភាព អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ៤០៣៨

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៧ ស្តីពីការតែងតាំងឯកឧត្តម **ចាន់ គីស៊ីម** បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំសាធារណរដ្ឋប៉ូឡូញ ឆែក ស្លូវ៉ាគ និង ហុងគ្រី អោយទទួលភារកិច្ចបន្ថែម ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំសាធារណរដ្ឋប៊ុលហ្គារី ដោយមានទិវេសនដ្ឋាននៅទីក្រុងវ៉ាសូវី នៃសាធារណរដ្ឋប៉ូឡូញ ៤០៤០

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **កៅ ខុនដារ៉េត** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៤០៤១

២៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៩៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **ថាំ សាន** នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៤០៤២

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤០៤៣

២៧-៦-២០០៥ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ ៤០៤៥

៣០-៦-២០០៥ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤០៤៨

៣០-៦-២០០៥ -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤០៥០

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤០អនក្រ.តត ស្តីពីការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈរាជាយស្វ័យយានកម្ពុជា ៤០៥២

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤០៥៣

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៥៥

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៥៦

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤០៥៧

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤០៥៨

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៥៩

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤០៦០

២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤០៦១
២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៤៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤០៦៤
២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤០៦៥
២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្តីពីការជូនមេដាយប្រាក់ការងារ ៤០៦៦
២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤០៦៧
២៤-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៦៨
-អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត មិនទាន់មានឯកសារ
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៧០
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៧១
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤០៧២
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៤០៨៦
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ៤០៨៧
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤០៨៨
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៨៩
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៩០
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៩២
២៨-៦-២០០៥ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤០៩៣
២៩-៦-២០០៥ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤០៩៤

២_សារាចរ

២៤-៦-២០០៥ -សារាចរលេខ ០៣ សរ ស្តីពីការគ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាពសុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី ៤០៩៥
៣០-៦-២០០៥ -សារាចរណែនាំលេខ ០៣ សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ៤០៩៨

III_ការិយាល័យបណ្ណាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣០-៦-២០០៥ -ប្រកាសលេខ ៣៩២សហវ ស្ដីពីការបង្កើតគណៈកម្មាធិការក្រុមការងារបច្ចេកទេសសំរាប់
រៀបចំធ្វើ ឯកជនភាវូបនីយកម្មក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ៤១១៣

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៦-២០០៥ -លិខិតលេខ ១៣៦៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ីលវើរ ស្ទេត អ៊ិនធើណេសិនណល ៤១១៥

១៤-៦-២០០៥ -លិខិតលេខ ១៣៧១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេស & អេ អ៊ិនធើប្រាយស៍ ខូ អិលធីឌី ៤១១៧

១៤-៦-២០០៥ -លិខិតលេខ ១៣៧២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ម៉ូះរ័ត្ន ត្រាវែល & ធួរ ៤១១៩

១៤-៦-២០០៥ -លិខិតលេខ ១៣៧៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ណេតវើក អេស៊ា អ៊ីន ៤១២១

១៤-៦-២០០៥ -លិខិតលេខ ១៣៧៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ូវ៉ាន់វ៉ារី ៤១២៣

១៤-៦-២០០៥ -លិខិតលេខ ១៣៨០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
រស្មី មានជ័យ ៤១២៥

១៤-៦-២០០៥ -លិខិតលេខ ១៣៨២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឯកឌីហ្សាញ គ្រុប ៤១២៧

១៤-៦-២០០៥ -លិខិតលេខ ១៣៨៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប៊ូដហ៊ី អ៊ិនធើប្រាយ ខូ អិលធីឌី ៤១២៩

ព្រះរាជក្រម

នស/រកម/០៦០៥/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ត្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្ដីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក
ស្ដីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហរដ្ឋអាមេរិកស្ដីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលធ្វើនៅទីក្រុងភ្នំពេញ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ស.០៥០៦.៧៩៧

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី
ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌
ហត្ថលេខា

អង្គ វង្សវឌ្ឍានា

លេខ ២៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

កិច្ចព្រមព្រៀង

រវាង

រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក

ស្តីពីការមិនប្រគល់ខ្លួន ជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលចាប់ពីពេលនេះតទៅហៅថា : "ភាគី"

ដោយបញ្ជាក់ជាថ្មីនូវសារៈសំខាន់នៃការនាំខ្លួនទៅកាត់ទោស ចំពោះជនទាំងឡាយដែលប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម

ដោយរំលឹកឡើងវិញថា លក្ខន្តិកៈក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានធ្វើនៅក្រុងរ៉ូមកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដោយសន្និសីទអង្គទូតពេញសមត្ថភាពរបស់អង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មានបំណងដើម្បីបន្ថែម ពុំមែនជំនួសយុត្តាធិការឧក្រិដ្ឋកម្មជាតិទេនោះ

ដោយចាត់ទុកថា រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសំដែងបំណងរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេត និងដើម្បីដាក់ទោសអោយបានសមស្របចំពោះអំពើដែលមន្ត្រី និយោជិក បុគ្គលិកយោធា ឬពលរដ្ឋណាមួយទៀតបានប្រព្រឹត្តិនៅក្រោមយុត្តាធិការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

ដោយប្រកាន់ខ្ជាប់នូវមាត្រាទី៩៨ នៃលក្ខន្តិកៈក្រុងរ៉ូម

ព្រមព្រៀងគ្នាដូចតទៅ :

១- តាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ "បុគ្គលទាំងឡាយ" ជាមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្ន ឬអតីតមន្ត្រីក្តី ជានិយោជិក (រួមទាំងបុគ្គលិកជាប់កិច្ចសន្យាផង) ឬបុគ្គលិកយោធា ឬពលរដ្ឋនៃភាគីមួយ ។

២- បុគ្គលទាំងឡាយនៃភាគីមួយដែលមានវត្តមាននៅលើទឹកដីនៃភាគីម្ខាងទៀត ដោយគ្មានការយល់ព្រមពីភាគីទីមួយ មិនត្រូវ :

ក- ប្រគល់ ឬផ្ទេរដោយមធ្យោបាយណាមួយ ទៅឱ្យតុលាការឧក្រិដ្ឋកម្មអន្តរជាតិក្នុងបំណងណាមួយឡើយ ឬ

ខ- ប្រគល់ ឬផ្ទេរដោយមធ្យោបាយណាមួយ ទៅឱ្យស្ថាប័នណាមួយ ឬប្រទេសទីពាណាមួយ ឬត្រូវបណ្តេញឱ្យទៅប្រទេសទីពាណាមួយ ក្នុងបំណងប្រគល់ខ្លួន ឬផ្ទេរខ្លួនឱ្យទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិឡើយ ។

៣- នៅពេលសហរដ្ឋអាមេរិកធ្វើបត្យាប័ន ប្រគល់ខ្លួន ឬក៏ផ្ទេរបុគ្គល ម្នាក់របស់ព្រះរាជាណាចក្រកម្ពុជា ទៅឱ្យប្រទេសទី៣ សហរដ្ឋអាមេរិកនឹងមិនយល់ព្រមប្រគល់ខ្លួន ឬផ្ទេរបុគ្គលរូបនោះ ទៅឱ្យតុលាការឧក្រិដ្ឋកម្មអន្តរជាតិ តាមការស្នើរបស់ប្រទេសទី៣ ដោយគ្មានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជាឡើយ ។

៤- នៅពេលរាជរដ្ឋាភិបាលកម្ពុជាធ្វើបត្យាប័ន ប្រគល់ខ្លួន ឬក៏ផ្ទេរ បុគ្គលម្នាក់របស់សហរដ្ឋអាមេរិកឱ្យទៅប្រទេសទី៣ រាជរដ្ឋាភិបាលកម្ពុជានឹងមិនយល់ព្រមប្រគល់ខ្លួន ឬផ្ទេរបុគ្គលរូបនោះ ទៅឱ្យតុលាការឧក្រិដ្ឋកម្មអន្តរជាតិ តាមការស្នើរបស់ប្រទេសទី៣ ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។

៥- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន បន្ទាប់ពីមានការផ្លាស់ប្តូរសារបញ្ជាក់ថាភាគីនីមួយៗបានបំពេញបែបបទច្បាប់របស់ខ្លួន តាមតម្រូវការចាំបាច់ចប់សព្វគ្រប់ ដើម្បីឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយកិច្ចព្រមព្រៀងនេះនឹងស្ថិតនៅជាធរមានរយៈពេលមួយ (០១)ឆ្នាំ រហូតដល់ពេលដែលភាគីណាមួយជូនពត៌មានដល់ភាគីមួយទៀត ដើម្បីបញ្ឈប់កិច្ចព្រមព្រៀងនេះ។ បទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ នឹងបន្តអនុវត្តចំពោះអំពើណាមួយដែលកើតមានឡើង ឬត្រូវបានចោទប្រកាន់ថាកើតមានឡើងមុនថ្ងៃបញ្ចប់សុពលភាពនៃកិច្ចព្រមព្រៀង ។

ជាសក្ខីភាព ហត្ថលេខីខាងក្រោមនេះ ត្រូវបានអនុញ្ញាតធ្វើជាតំណាងរដ្ឋាភិបាលនីមួយៗ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៥ខែមិថុនា ឆ្នាំ២០០៣ ចំនួនពីរច្បាប់ ជាភាសាអង់គ្លេស និងភាសាខ្មែរ ដែលអត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយមិនស្របគ្នា អត្ថបទជាភាសាអង់គ្លេសនឹងយកមកធ្វើជាគោល ។

តំណាងរាជរដ្ឋាភិបាលកម្ពុជា

ឯកឧត្តម ហោ ណាំហុង
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

តំណាងរដ្ឋាភិបាលសហរដ្ឋអាមេរិក

ឯកឧត្តម ឆាល អារ៉ុន រ៉េ
ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក
ប្រចាំព្រះរាជាណាចក្រកម្ពុជា

AGREEMENT
BETWEEN THE ROYAL GOVERNMENT OF CAMBODIA AND THE GOVERNMENT OF THE UNITED STATES OF AMERICA REGARDING THE NON-SURRENDER OF PERSONS TO THE INTERNATIONAL CRIMINAL COURT

The Royal Government of Cambodia and the Government of the United States of America, hereinafter referred to as " The Parties",

Reaffirming the importance of bringing to justice those who commit genocide, crimes against humanity and war crimes,

Recalling that the Rome Statute of the International Criminal Court done at Rome on July 17, 1998 by the United Nations Diplomatic Conference of Plenipotentiaries on the Establishment of an International Criminal Court is intended to complement and not supplant national criminal jurisdiction,

Considering that the Government of the United States of America expressed its intention to investigate and to prosecute where appropriate acts within the jurisdiction of the International Criminal Court alleged to have been committed by its officials, employees, military personnel or other nationals,

Bearing in mind Article 98 of the Rome Statute,

Hereby agree as follows :

1- For purpose of this agreement, " persons " are current or former Government officials, employees (including contractors), or military personnel or nationals of one Party.

2- Persons of one Party present in the territory of the other shall not, without the expressed consent of the first Party,

(a) be surrendered or transferred by any means to the International Criminal Court for any purpose, or .
(b) be surrendered or transferred by any means to any other entity or third country, or expelled to a third country, for the purpose of surrender to or transfer to the International Criminal Court.

3- When the United States extradites, surrenders, or otherwise transfers a person of the Kingdom of Cambodia to a third country, the United States will not agree to the surrender or transfer of that person to the International Criminal Court

by the third country, without the expressed consent of the Royal Government of Cambodia.

4- When the Royal Government of Cambodia extradites, surrenders, or otherwise transfers a person of the United States of America to a third country, the Royal Government of Cambodia will not agree to the surrender or transfer of that person to the International Criminal Court by a third country, without the expressed consent of the Government of the United States.

5- This Agreement shall enter into force upon an exchange of notes confirming that each Party has completed the necessary domestic legal requirements to bring the Agreement into force. It will remain in force until one (01) year after the date on which one Party notifies the other of its intent to terminate this Agreement. The provisions of this Agreement shall continue to apply with respect to any act occurring, or any allegation arising, before the effective date of termination.

IN WITNESS WHEREOF, the undersigned, being duly authorized by their respective Governments, have signed this present Agreement.

DONE at Phnom Penh, this 27th.day of June 2003 in duplicate in English and Khmer languages, both texts being equally authentic. In case of any divergence of interpretation, the English text shall prevail.

FOR THE ROYAL GOVERNMENT OF CAMBODIA

HOR Namhong
Senior Minister
Minister of Foreign Affairs and International Cooperation

FOR THE GOVERNMENT OF THE UNITED STATES OF AMERICA

Charles Aaron Ray
Ambassador of the United States of America to the Kingdom of Cambodia

ព្រះរាជក្រម

នស/រកម/០៦០៥/០១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់ធម្មនុញ្ញ
ស្តីពី
វិសោធនកម្មមាត្រា ៧៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ

មាត្រាតែមួយ.-

មាត្រា ៧៨ និងមាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ :

មាត្រា ៧៨ ថ្មី.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

314

មាត្រា ១១១ ថ្មី (មួយ).–

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកម.០៦០៥.២៩៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខ ២៧៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ ឥសាន

4/4

ព្រះរាជក្រម

នស/រកម/០៦០៥/០២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ និងព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧០/០០២/២០០៥/កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការបោះឆ្នោតជ្រើសតាំង

សមាជិកព្រឹទ្ធសភា

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំបែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោតនិងមណ្ឌលបោះឆ្នោត ។

មាត្រា ២.-

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៣.-

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

មាត្រា ៤.-

សមាជិកព្រឹទ្ធសភាចំនួន ០២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

មាត្រា ៥.-

សមាជិកព្រឹទ្ធសភាចំនួន ០២ រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

មាត្រា ៦.-

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ជំពូកទី ២

ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត ការបែងចែកអាសនៈ អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោត

មាត្រា ៧.—

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ថ្មី នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៨.—

ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា ១១៨ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ៩.—

មណ្ឌលបោះឆ្នោតត្រូវរៀបចំជាភូមិភាគដែលមានតារាងកំណត់ដូចខាងក្រោម :

- ភូមិភាគទី ១ ក្រុងភ្នំពេញ
- ភូមិភាគទី ២ ខេត្តកំពង់ចាម
- ភូមិភាគទី ៣ ខេត្តកណ្តាល
- ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន
- ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងក្រុងកែប
- ភូមិភាគទី ៦ ខេត្តព្រៃវែង និងស្វាយរៀង
- ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ
- ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី

មាត្រា ១០.-

០៦ ខែយ៉ាងតិចមុនចប់នីតិកាល ព្រឹទ្ធសភាត្រូវអនុម័តកំណត់ចំនួនអាសនៈនិងការបែងចែកអាសនៈ តាមភូមិភាគនីមួយៗសម្រាប់នីតិកាលបន្ទាប់ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ ។

ក្នុងករណីខកខានពុំបានកំណត់ជាថ្មីនូវអាសនៈក្នុងព្រឹទ្ធសភា ចំនួនអាសនៈតាមភូមិភាគនោះ ត្រូវយកតាមចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

មាត្រា ១១.-

អ្នកបោះឆ្នោត និងអង្គបោះឆ្នោតគឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

មាត្រា ១២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីអ្នកបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីអ្នកបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយមិនអាចកែប្រែបានទេ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូងយ៉ាងតិច ៤៨ (សែសិបប្រាំបី) ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនខេត្ត-ក្រុង ។

មាត្រា ១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោតនៅទីប្រជុំជនខេត្ត-ក្រុងនីមួយៗ ។

ជំពូកទី ៣

ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ

មាត្រា ១៤.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើម ៩០(កៅសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

មាត្រា ១៥.–

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀងដូចជាការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

មាត្រា ១៦.–

បែបបទ លក្ខខណ្ឌនិងនីតិវិធីទាំងឡាយស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៤

បេក្ខជនសមាជិកព្រឹទ្ធសភា

មាត្រា ១៧.–

មាត្រា៣៣ថ្មី ៣៤ថ្មី ៣៥ថ្មី ៣៦ថ្មី ៣៧ថ្មី ៣៨ថ្មីនិងមាត្រា៣៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦-១២-១៩៩៧ និងព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧-០៩-២០០២ ត្រូវយកមកអនុវត្តចំពោះបេក្ខជនសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ ។

ជំពូកទី ៥

ការឃោសនាបោះឆ្នោត

មាត្រា ១៨.–

ការឃោសនាបោះឆ្នោតមានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយនិងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

មាត្រា ១៩.-

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

មាត្រា ២០.-

មាត្រា ៧១ ៧៣ ៧៤ ៧៥ ៧៦ ៧៧ ៨០ ៨១ ៨២ និងមាត្រា ៨៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៦

តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

មាត្រា ២១.-

មាត្រា ២៦ថ្មី ២៧ ២៨ និងមាត្រា ២៩ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៧

ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និង ការបូកសរុបលទ្ធផលនៃការបោះឆ្នោត

មាត្រា ២២.-

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ២៣.-

តាមរយៈក្របខ័ណ្ឌនៃអំណាចដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចកំណត់បទបញ្ញា និង

នីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបន្ថែមលើភារកិច្ចបច្ចុប្បន្ននេះ ។

មាត្រា ២៤.-

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹករហូតដល់ម៉ោង ១៥:០០ (ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង ១៥:០០ (ដប់ប្រាំ) ។

ប្រធានការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោតមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ហើយអាចអនុញ្ញាតឱ្យបោះឆ្នោតគឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

មាត្រា ២៥.-

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែងក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

មាត្រា ២៦.-

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

មាត្រា ២៧.–

បែបបទ នីតិវិធីផ្សេងៗទៀតនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៨

សមត្ថកិច្ចដោះស្រាយការវិវាទ ស្តីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា

មាត្រា ២៨.–

គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោតជាអ្នកសម្រេចដំបូងបង្អស់លើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្នុងករណីមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមត្ថកិច្ចពិនិត្យនិងសម្រេច ។

មាត្រា ២៩.–

ក្នុងករណីមានបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ាលើការវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ៣០.–

នីតិវិធីដោះស្រាយការវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយការវិវាទស្តីពីការបោះឆ្នោតជ្រើស

តាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃគាំនិងការសម្រេចលើបណ្តឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

ជំពូកទី ៩
ករណីជ្រើសតាំងជំនួសសមាជិកព្រឹទ្ធសភា

មាត្រា ៣១.-

សមាជិកព្រឹទ្ធសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម :

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកព្រឹទ្ធសភា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន

កាលបើសមាជិកព្រឹទ្ធសភាណាមួយត្រូវបាត់បង់សមាជិកភាព មានរយៈពេល ៦ (ប្រាំមួយ)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

ជំពូកទី ១០

វិវាទ

មាត្រា ៣២.—

មាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ១១

ទោសប្បញ្ញត្តិ

មាត្រា ៣៣.—

មាត្រា ១២៤ថ្មី ១២៥ថ្មី ១២៦ថ្មី ១២៧ថ្មី ១២៨ថ្មី ១២៩ថ្មី ១៣០ថ្មី ១៣១ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ១២

អន្តរប្បញ្ញត្តិ

មាត្រា ៣៤.—

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ២ នៃព្រឹទ្ធសភាត្រូវប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី ២២ ខែ មករា ឆ្នាំ ២០០៦ ។

មាត្រា ៣៥.—

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី ២២ ខែ មករា ឆ្នាំ ២០០៦ ចំនួនអាសនៈនៃព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំងត្រូវកំណត់ត្រឹម ៥៧(ហាសិបប្រាំពីរ) ។ ចំនួនអាសនៈតាមភូមិភាគមានដូចខាងក្រោម :

-ភូមិភាគទី ១	ក្រុងភ្នំពេញ	មាន ៦ អាសនៈ
-ភូមិភាគទី ២	ខេត្តកំពង់ចាម	មាន ៨ អាសនៈ
-ភូមិភាគទី ៣	ខេត្តកណ្តាល	មាន ៥ អាសនៈ

-ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មាន១០ អាសនៈ

-ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងក្រុងកែប មាន ៧ អាសនៈ

-ភូមិភាគទី ៦ ខេត្តព្រៃវែង និងស្វាយរៀង មាន ៧ អាសនៈ

-ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ មាន ៨ អាសនៈ

-ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី មាន ៦ អាសនៈ

ចំនួនអាសនៈនេះត្រូវផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ ។

ជំពូកទី ១៣

អវសានប្បញ្ញត្តិ

មាត្រា ៣៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៧.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥

ពរល.០៥០៦.០៣០

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខៈ ៧៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ព្រះរាជក្រម

នស/រកម/០៦០៥/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងមហាអនុតំបន់មេគង្គ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៥០៦.០២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

ស៊ុយ សែម

លេខ ២៦៥-ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

3/3

មហាអនុតំបន់មេគង្គ

កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

ស្តីពី

ពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

បកប្រែក្រៅផ្លូវការ

កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល
ស្តីពី
ពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

បុព្វកថា

រដ្ឋាភិបាលនៃបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ដែលតទៅហៅកាត់ថា GMS) រួមមានៈ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ដែលតទៅ ហៅកាត់ថា បណ្តាភាគី) ។

ដោយទទួលស្គាល់ថា សហគ្រាសថាមពលអគ្គិសនីជាតិនៃបណ្តាប្រទេស GMS កំពុងទទួលបន្ទុកធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសរៀងៗខ្លួន និងមានបំណងពង្រីកអាជីវកម្ម ដោយអភិវឌ្ឍការតភ្ជាប់រវាងប្រព័ន្ធបណ្តាញជាតិរបស់ខ្លួនទៅវិញទៅមកព្រមទាំងពង្រីកសមត្ថភាព និងពាណិជ្ជកម្មថាមពលអគ្គិសនី ដើម្បីផ្តល់ឱកាសច្រើនថែមទៀតក្នុងការៈ (១)បង្កើនការទុកចិត្តចំពោះការផ្គត់ផ្គង់ (២)សំរបសំរួលការតំឡើង និងកិច្ចប្រតិបត្តិការមធ្យោបាយផលិតកម្ម និងប្រព័ន្ធបញ្ជូន (៣)កាត់បន្ថយទុនវិនិយោគ និងថ្លៃដើមប្រតិបត្តិការ និង (៤) បែងចែកផលប្រយោជន៍ផ្សេងទៀតដែលបានមកពីប្រតិបត្តិការនៃការតភ្ជាប់ប្រព័ន្ធបណ្តាញរបស់ខ្លួន។

ដោយយល់ឃើញថាបណ្តាប្រទេសសមាជិក GMS ដែលបានទទួលស្គាល់ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការរវាងផ្នែកថាមពលអគ្គិសនីជាតិរបស់ខ្លួន បានរៀបចំបង្កើតវេទិកាថាមពលអគ្គិសនី (Electric Power Forum-EPF) ក្នុងឆ្នាំ ១៩៩៥ និងក្រុមអ្នកជំនាញខាងការតភ្ជាប់ប្រព័ន្ធបណ្តាញ និងពាណិជ្ជកម្មថាមពលអគ្គិសនី (Experts Group on Power Interconnection and Trade-EGP) ក្នុងឆ្នាំ ១៩៩៨ ដើម្បីសិក្សានិងផ្តល់អនុសាសន៍លើការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីក្នុង GMS ។

ដោយចងចាំថា ក្នុងកិច្ចប្រជុំទី៩ថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងម៉ានីលក្នុងខែមករាឆ្នាំ ២០០០ ដែលរដ្ឋមន្ត្រីនៃបណ្តាប្រទេស GMS បានអនុម័ត " សេចក្តីថ្លែងការណ៍គោលនយោបាយ ស្តីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ " ក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីចំពោះកន្លែងមានលក្ខណៈសេដ្ឋកិច្ចល្អ ។ ក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយ រដ្ឋមន្ត្រីនៃបណ្តាប្រទេស GMS បានឯកភាពថា រដ្ឋាភិបាលណាដែលចង់ឱ្យផ្នែកថាមពលអគ្គិសនីរបស់ខ្លួនចូលរួមក្នុងពាណិជ្ជកម្មតំបន់ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ដើម្បីផ្តល់ក្របខណ្ឌការងារសម្រាប់អនុវត្តសេចក្តីថ្លែងការណ៍គោលនយោបាយនេះ ។

ដូច្នេះ តាមរយៈតំណាងរបស់ខ្លួន ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវជាហត្ថលេខីនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ បណ្តាភាគីព្រមព្រៀងដូចតទៅៈ

បកប្រែក្រៅផ្លូវការ

មាត្រា ១ : គោលបំណងនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

១.១ គោលបំណងនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ គឺអនុវត្តសេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនី ដែលបានអនុមត់ដោយរដ្ឋមន្ត្រីនៃបណ្តាប្រទេស GMS ក្នុងខែ មករា ឆ្នាំ ២០០០ រួមទាំងការបង្កើតក្របខណ្ឌការងារ ដែលបណ្តាភាគីមានផែនការជំរុញពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (GMS) ។ សេចក្តីថ្លែងការគោលនយោបាយត្រូវបានបញ្ចូលជាឧបសម្ពន្ធ (ក) នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។

មាត្រា ២: គោលការណ៍និងទិសដៅពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ

២.១ គោលការណ៍និងទិសដៅក្នុងមាត្រានេះ គឺស្របតាមការអនុវត្តន៍ទិសដៅនៃសេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ក្នុងមហាអនុតំបន់មេគង្គដូចដែលមានចែងក្នុងឧបសម្ព័ន្ធ (ក) ។

២.២ បណ្តាភាគីយល់ព្រមថា ទំនាក់ទំនងរបស់ខ្លួនត្រូវផ្អែកលើគោលការណ៍ដូចតទៅ :

ក) សហប្រតិបត្តិការ : បញ្ហាទាក់ទងនឹងការតភ្ជាប់នេះត្រូវដោះស្រាយក្នុងស្មារតីសហប្រតិបត្តិការនិងផលប្រយោជន៍ទៅវិញទៅមក បណ្តាភាគីមានសិទ្ធិនិងកាតព្វកិច្ចស្មើគ្នា ធ្វើសកម្មភាពជាសាមគ្គីភាព និងទប់ស្កាត់រាល់ការដណ្តើមយកអត្ថប្រយោជន៍រៀង១ខ្លួន ។

ខ) ភាពឈានឡើង : បណ្តាភាគីយកចិត្តទុកដាក់ការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃពាណិជ្ជកម្មអគ្គិសនីតំបន់ និង

គ) ការអភិវឌ្ឍន៍និរន្តភាពជាលក្ខណៈបរិស្ថាន : ពោលគឺពាណិជ្ជកម្មអគ្គិសនីតំបន់ត្រូវបានដំណើរការក្នុងល័ក្ខខ័ណ្ឌមួយនៃការគោរពបរិស្ថាន ។

២.៣ ទិសដៅពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលគឺសំរាប់អ្នកចូលរួមទាំងអស់ដើម្បី :

ក) សំរបសំរួល និង សហប្រតិបត្តិការក្នុងការងារផែនការ និងដំណើរការប្រពន្ធ័របស់ខ្លួន ដើម្បីបន្ថយជាអប្បរមាថ្លៃដើម ដោយធានាបាននូវការទុកចិត្ត និង

ខ) ទូទាត់ថ្លៃដើមរបស់ខ្លួនបានទាំងស្រុង និងបែងចែកដោយសមធម៌ផលចំណេញដែលទទួលបាន ដោយរួមបញ្ចូលទាំងការកាត់បន្ថយសមត្ថភាពផលិតកម្មនិងការបញ្ជូនដែលបានតំរូវការកាត់បន្ថយចំណាយប្រេង និងការប្រើប្រាស់កាន់តែប្រសើរឡើងនៃប្រភពអគ្គិសនីថ្លៃទាប និង

គ) ផ្តល់សេវាកម្មអគ្គិសនីជាទីទុកចិត្ត និងប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចដល់អតិថិជនរបស់ភាគីនីមួយ១ ។

មាត្រា៣ : និយមន័យ

៣.១ ឧបសម្ពន្ធ័ (Annex) - ឯកសារភ្ជាប់ជាមួយកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ដែលជាផ្នែកសរុបមួយនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ។

បកប្រែក្រៅផ្លូវការ

៣.២ ទីភ្នាក់ងារបានអនុញ្ញាត (Authorized Agency) - ទីភ្នាក់ងារដែលបានចាត់តាំងដោយបណ្ដាភាគីដើម្បីអនុវត្ត កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។

៣.៣ វេទិកាថាមពលអគ្គិសនី (Electric Power Forum - EPF) - ក្រុមថាមពលអគ្គិសនីដែលបានបង្កើតឡើងអនុលោម តាមកម្មវិធី GMS ក្នុងឆ្នាំ ១៩៩៥ ។

៣.៤ ក្រុមអ្នកជំនាញខាងការតភ្ជាប់ប្រព័ន្ធបណ្ដាញ និងពាណិជ្ជកម្មថាមពលអគ្គិសនី (Experts Group on Power Interconnection and Trade - EGP) - ក្រុមអ្នកជំនាញមកពីសហគ្រាសថាមពលអគ្គិសនី និងរដ្ឋាភិបាលសមាជិក GMS និងដែលបានបង្កើតឡើងដោយវេទិការថាមពលអគ្គិសនីក្នុងឆ្នាំ ១៩៩៨ ។

៣.៥ កម្មវិធីនៃមហាអនុតំបន់មេគង្គ (GMS Program) - កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចសំរាប់មហាអនុតំបន់មេគង្គ ដែលបានផ្ដួចផ្ដើមឡើងក្នុងឆ្នាំ ១៩៩២ ។

៣.៦ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសក្នុងមហាអនុតំបន់មេគង្គ (GMS Ministerial Meeting) - កិច្ចប្រជុំ ប្រចាំឆ្នាំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសក្នុងមហាអនុតំបន់មេគង្គដែលបានរៀបចំជាផ្នែកមួយនៃកម្មវិធីរបស់ GMS ដើម្បី សម្របសម្រួលកិច្ចសហប្រតិបត្តិការអនុតំបន់ និង ផ្ដល់ការណែនាំ និង ការគាំទ្រទាំងមូល ។

៣.៧ គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (Regional Power Trade Coordination Committee-RPTCC) - គណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់បង្កើត ឡើងដើម្បីសម្របសម្រួលការអនុវត្តន៍ពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ស្របតាមកិច្ចព្រមព្រៀងនេះ ។

៣.៨ មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) - ព្រះរាជាណាចក្រកម្ពុជា ខេត្តយូណាននៃ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

៣.៩ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល (Inter-Governmental Agreement) - កិច្ចព្រមព្រៀងនេះរួមជាមួយនឹង ឧបសម្ពន្ធ័ក្នុងចំណោមព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិត ឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

៣.១០ កិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ (Regional Power Trade Operating Agreement PTOA)-ជាកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្ម និង បច្ចេកទេសសំរាប់ការអនុវត្តន៍ និង ប្រតិបត្តិការ ពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ ក្នុងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះដែលនឹងត្រូវព្រាងនៅក្រោមការគ្រប់គ្រងរបស់ (RPTCC)

៣.១១ បណ្ដាភាគី (Parties) - រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហព័ន្ធភូមា ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

បកប្រែក្រៅផ្លូវការ

៣.១២ សេចក្តីថ្លែងការណ៍គោលនយោបាយស្តីពីពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ក្នុងមហាអនុតំបន់មេគង្គ (Policy Statement on Regional Power Trade in the Greater Mekong Sub-region) - ជាសេចក្តីថ្លែងការណ៍ដែលបានអនុមត័ដោយកិច្ចប្រជុំទី ៩ ថ្នាក់រដ្ឋមន្ត្រី GMS នៅទីក្រុងម៉ានីល ក្នុងខែ មករា ឆ្នាំ ២០០០។

មាត្រា៤ : គ្រប់ខណ្ឌការងារស្ថាប័ន

៤.១ បណ្តាភាគីត្រូវផ្ទេរការទទួលខុសត្រូវលើការដឹកនាំ និងពិនិត្យតាមដាននៃការធ្វើពាណិជ្ជកម្មតំបន់តាមកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ទៅឱ្យរដ្ឋមន្ត្រីដែលទទួលខុសត្រូវខាងផ្នែកអគ្គិសនី ឬគោលនយោបាយអគ្គិសនីឱ្យបានសមស្រប ។ រដ្ឋមន្ត្រីទាំងនោះត្រូវជួបប្រជុំនៅពេលដែលយល់ថាចាំបាច់ ឬតាមការស្នើសុំរបស់ប្រធានគណៈកម្មការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (RPTCC) ដែលនឹងត្រូវបង្កើតដោយអនុលោមតាមមាត្រាទី ៤-២ នៃកិច្ចព្រមព្រៀងនេះ ។

៤.២ បណ្តាភាគីត្រូវទទួលស្គាល់តម្រូវការចាំបាច់សំរាប់អង្គការជាន់ខ្ពស់ គឺគណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងមហាអនុតំបន់មេគង្គ (RPTCC) ដើម្បីសម្របសម្រួលយ៉ាងសកម្មឱ្យបានជោគជ័យដល់ការអនុវត្តន៍ពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ និងជាតំណាងឱ្យបណ្តាប្រទេសដែលជាប់ទាក់ទងនឹងពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ ។ បណ្តាភាគីត្រូវចាត់តាំងតំណាងជាតិរបស់ខ្លួនសំរាប់វេទិកាថាមពលអគ្គិសនីបច្ចុប្បន្ន ដើម្បីបង្កើតឡើងគណៈកម្មាធិការ RPTCC បណ្តោះអាសន្នទី ១ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ គណៈកម្មាធិការ RPTCC នឹងរាយការណ៍ជូនសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រី GMS និងរដ្ឋាភិបាលជាតិរៀងៗខ្លួន តាមរយៈរដ្ឋមន្ត្រីដែលមានចែងក្នុងមាត្រា៤.១ នៃកិច្ចព្រមព្រៀងនេះ ។ គណៈកម្មាធិការ RPTCC នឹងមានឯករាជ្យភាពក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួនសំរាប់គោលបំណងនៃការសម្រេចបាននិសដៅដ៏ចំបងរបស់ខ្លួន ។ ក្រុមអ្នកជំនាញលើការតភ្ជាប់ និងពាណិជ្ជកម្មថាមពលអគ្គិសនីបច្ចុប្បន្នត្រូវផ្តល់ការគាំទ្របច្ចេកទេសដល់គណៈកម្មាធិការ RPTCC។

៤-៣ តួនាទីរបស់គណៈកម្មាធិការ RPTCC - មុខងារទី១របស់ RPTCC គឺកំណត់ឱ្យបានកាន់តែច្បាស់ នូវជំហានទី១ ក្នុងការបង្កើត និងការអនុវត្តន៍ការរៀបចំពាណិជ្ជកម្មតំបន់ដែលនឹងត្រូវដាក់ជូនបណ្តាភាគីដើម្បីអនុម័ត ។ ឯកសារនេះត្រូវរួមបញ្ចូលទាំងផែនការដើម្បីសម្រេចការងារដូចតទៅ :

ក) ផ្តល់ដល់បណ្តាភាគីសេចក្តីព្រាងចុងក្រោយ នៃកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ PTOA ដែលនឹងត្រូវកំណត់ជាកំលាក់បទបញ្ជានៃពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់

ខ) ផ្តល់ដល់បណ្តាភាគីនូវអនុសាសន៍សំរាប់គោលនយោបាយទាំងមូល និងការគ្រប់គ្រងប្រចាំថ្ងៃនៃពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ រួមបញ្ចូលទាំងអង្គភាពចាំបាច់សំរាប់ការសម្របសម្រួល

គ) បង្កើតគំនិតផ្តួចផ្តើមរយៈពេលខ្លី មធ្យម និងវែង ដែលត្រូវការចាំបាច់អនុវត្តលើមូលដ្ឋានអាទិភាព ដើម្បីសម្រេចបាននិសដៅនៃការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់នៅក្នុងតារាងពេលវេលាជាកំលាក់មួយ និង

បកប្រែក្រៅផ្លូវការ

ឃ) រកឱ្យឃើញជំហានចាំបាច់ សំរាប់ការអនុវត្តន៍ពាណិជ្ជកម្មតំបន់ រួមទាំងមធ្យោបាយសំរាប់ហិរញ្ញប្បទាន ។

៤.៤ បណ្ដាភាគីក៏ត្រូវអនុញ្ញាតិឱ្យអាជ្ញាធរ និង សហគ្រាសអគ្គិសនីជាតិដែលបានចាត់តាំង ដើម្បីចូលរួមក្នុងកិច្ចព្រមព្រៀងចាំបាច់ ដើម្បីបញ្ចតិការបង្កើត និង ប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ រួមទាំងកិច្ចព្រមព្រៀងប្រតិបត្តិការពាណិជ្ជកម្មថាមពលអគ្គិសនីតំបន់ (PTOA) ដែលត្រូវដាក់ជូនគណៈកម្មាធិការ RPTCC ដើម្បីសម្រេច ។ បណ្ដាភាគីត្រូវគាំទ្រ និង ជួយដល់អាជ្ញាធរ និង សហគ្រាសអគ្គិសនីជាតិដែលបានចាត់តាំងរៀង១ខ្លួន ក្នុងការអនុវត្តន៍ និងប្រតិបត្តិការកាតព្វកិច្ចរបស់ខ្លួន ក្នុងលក្ខខ័ណ្ឌដែលកិច្ចព្រមព្រៀងណាមួយបានចុះកិច្ចព្រមព្រៀងរវាងសហគ្រាសថាមពលអគ្គិសនីរៀង១ខ្លួន ស្របតាមកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ និងអនុលោមតាមសេចក្ដីថ្លែងការណ៍គោលនយោបាយ ។

មាត្រា៥ : បណ្ដាភាគីនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល

៥.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ បើកចំហរដល់ការចុះហត្ថលេខាដោយប្រទេសសមាជិករបស់ GMS ទាំងអស់ ។

៥.២ ការបញ្ចូលបន្ថែមបណ្ដាប្រទេសមិនមែនជាសមាជិក GMS ត្រូវដាក់ពាក្យស្នើសុំសម្រេចទៅបណ្ដាភាគី GMS ទាំងអស់នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ ល័ក្ខខ័ណ្ឌសំរាប់បញ្ចូលសមាជិកថ្មីនេះនឹងត្រូវធ្វើជាកិច្ចព្រមព្រៀងដោយឡែក ដែលនឹងត្រូវជាផ្នែកភ្ជាប់មកជាមួយនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ។

មាត្រា៦ : ការដោះស្រាយវិវាទ

ភ្នាក់ងារដែលបានអនុញ្ញាតិឱ្យអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវស្វែងរកដំណោះស្រាយប្រកបដោយភាតរភាពរយៈការពិគ្រោះយោបល់ចំពោះភាពមិនស្របគ្នាណាមួយក្នុងការបកស្រាយ ឬការអនុវត្តន៍នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ។ ក្នុងករណីដែលភ្នាក់ងារមានសិទ្ធិមិនអាចដោះស្រាយបញ្ហាណាមួយដោយភាតរៈបាន បញ្ហានេះត្រូវបញ្ជូនទៅបណ្ដាភាគីដើម្បីដោះស្រាយ ។

មាត្រា៧ : សច្ចានុម័ត និង ការចូលជាធរមាន

៧.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះត្រូវធ្វើសច្ចានុម័ត ឬយល់ព្រមដោយបណ្ដាភាគីដោយអនុលោមតាមនិតិវិធីជាតិរៀង១ខ្លួន ។ បណ្ដាភាគីត្រូវពិនិត្យមើល និង ធ្វើឱ្យបានរួសរាន់ការធ្វើសច្ចានុម័ត ឬ ដំណើរការសម្រេចយល់ព្រមនៅក្នុងអង្គការជាតិរៀង១ខ្លួន ។ ភាគីនីមួយៗត្រូវជូនដំណឹងអំពីការធ្វើសច្ចានុម័ត ឬការយល់ព្រមទៅបណ្ដាភាគីផ្សេងទៀត។

បកប្រែក្រៅផ្លូវការ

៧.២ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះ ត្រូវចូលជាធរមានរវាង និងក្នុងចំណោមភាគីដែលបានធ្វើសច្ចានុម័ត ឬយល់ព្រមលើកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល នៅក្នុងកាលបរិច្ឆេទនៃការចេញឯកសារឧបករណ៍ទីបី នៃការធ្វើសច្ចានុម័ត ឬ ការយល់ព្រម ។

មាត្រា៨ : ថេរវេលានៃកិច្ចព្រមព្រៀង

៨.១ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនេះនឹងនៅមានប្រសិទ្ធភាពរហូតដល់មានការកែសំរួល ឬការបញ្ចប់ដោយបណ្តាភាគី ។

មាត្រា ៩ : ការដកខ្លួនចេញពីកិច្ចព្រមព្រៀង

- បានឃើញព្រះរាជក្រមលេខ នស / រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .-

ត្រូវបានបន្ថែមក្របខ័ណ្ឌចំនួន ០១ កន្លែង មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ សំរាប់លោកស្រី ញ៉ៀម មរតន ។

មាត្រា ២ .-

ក្របខ័ណ្ឌបន្ថែមថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិ ចាប់ពីខែ សីហា ឆ្នាំ ២០០៥ តទៅ ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង
នាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ជួន ធឿន** អត្តលេខ ០៤៥០ បច្ចុប្បន្នអនុប្រធានអង្គភាពអន្តរាគមន៍ នៃក្រសួងមហាផ្ទៃ ទៅជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហ-រដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៦០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .-

ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ម៉ុន សេម៉ឺន** អត្តលេខ ០៥០៩

២- លោកវរសេនីយ៍ទោ **ជា ស៊ឿន** អត្តលេខ ០៦៧៦

៣- លោកវរសេនីយ៍ទោ **ឈុប គឹមហេង** អត្តលេខ ០៩០៤

៤- លោកវរសេនីយ៍ទោ **ឃាត់ គីម៉ុង** អត្តលេខ ០៩០៥

៥- លោកវរសេនីយ៍ទោ **នឹម យ៉ារ៉ុម** អត្តលេខ ០១៥៦៣ ។

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម និងសប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់អគារសិក្សា ០២ខ្នង នៅខេត្តកំពង់ធំ ដូចមានខាងក្រោម :-

១-*សមាគមស្ម័គ្រចិត្តអន្តរជាតិ ស៊ូតូស៊ូ* នៃ ខេត្តតូជីគី ប្រទេសជប៉ុន បានផ្តល់ថវិកា ចំនួន ១៦.៨៦៩ *USD* ជួយកសាងអគារសិក្សា ០១ខ្នង បង្គន់អនាម័យ អណ្តូងទឹក និង សម្ភារៈផ្សេងៗ នៅសាលាបឋមសិក្សាខ្ទាត់ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

២-លោកស្រី *MARIKO OKAMURA* ប្រធានអង្គការ *ASAC* បានផ្តល់ថវិកា ចំនួន ២៦.០០០ *USD* ជួយកសាងអគារសិក្សា ០១ខ្នង បង្គន់អនាម័យ របង ខ្លោងទ្វារ ដងទង់ជាតិ និង សម្ភារៈផ្សេងៗ នៅសាលាបឋមសិក្សា ត្រពាំងថ្ម ឃុំត្រពាំងឬស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

SR/31

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៦៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១១គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានជួយកសាង ផ្លូវលំមួយខ្សែ ស្ពានបេតុងមួយ និង ព្រះវិហារ វត្តបឹងព្រះ ឃុំកំពង់ក្រែង ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

-លោកវរសេនីយ៍ឯក អ៊ូ ហៃ		ស្នងការនគរបាលខេត្តកំពត	ថវិកា ១៣.៥០០ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-លោកស្រី	ជុំ ខឹត	អាជីវករ នៅខេត្តកំពត	ថវិកា ៥.៥០០ ដុល្លារ
២-លោក	ខួន សុផល	អាជីវករ នៅខេត្តកំពត	ថវិកា ៥.៣០០ ដុល្លារ
៣-លោក	ហេង ឡេង	អាជីវករ នៅខេត្តកំពត	ថវិកា ៥.១៥០ ដុល្លារ

គ.មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក	ឡាយ ផេង	អាជីវករ នៅខេត្តកំពត	ថវិកា ២.០០០ ដុល្លារ
២-លោក	នួន ហួន	អាជីវករ នៅខេត្តកំពត	ថវិកា ២.០០០ ដុល្លារ
៣-លោក	អ៊ុំ ម៉េងហ៊ួរ	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពត	ថវិកា ១.៨០០ ដុល្លារ

៤-លោក	**លឹម សំបូរ**	ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកំពត	ថវិកា	១.៨០០ ដុល្លារ
៥-លោក	**ទ៊ា ស៊ីណា**	អាជីវករ នៅខេត្តកំពត	ថវិកា	១.៨០០ ដុល្លារ
៦-លោក	**ឈី ស្រេង**	អាជីវករ នៅខេត្តកំពត	ថវិកា	១.៧៤០ ដុល្លារ
៧-លោកវរសេនីយ៍ត្រី	**អ៊ឹម ឈួន**	ប្រធានការិយាល័យជនបរទេស	ថវិកា	១.៧០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

B/45-46 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ***WATANABE MIKI*** ប្រធានអង្គការ ***SCHOOL AID JAPAN*** ដែលបានផ្តល់ថវិកា ចំនួន ២៩.៦២៥ ***USD*** សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សា បឹងកន្ទួត ក្នុងឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

B/39

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក *WATANABE MIKI* ប្រធានអង្គការ *SCHOOL AID JAPAN* ដែលបានផ្តល់ថវិកា ចំនួន ២៥.០០០ *USD* សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សា សូភី ក្នុងឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តពោធិ៍សាត់ ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Sr/35

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៩ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សរិទ្ធិ** ជូននាយទាហាន នៃក្រុមបេសកកម្មយោធាបារាំង ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយអភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទ ដូចមាននាមខាងក្រោម :-

1-Lieutenant – Colonel Alain BROSSARD
2-Lieutenant – Colonel Richard DUMONT
3-Commandant Jean – Marie LAPERLE
4-Capitaine François DICKES
5-Adjudant-Chef Serge PERONET
6-Sergent-Chef David BADIN

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.103 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ សរ.ណ

សារាចរ

ស្តីពី

ការគ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី

កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចេញនូវអនុក្រឹត្យ និងលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា ជាពិសេសផលិតផលចំណីអាហារដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកមួយចំនួន ដែលមានប្រើសារជាតិគីមី ដើម្បីក្លែងបន្លំគុណភាព ។ រាជរដ្ឋាភិបាល បានធ្វើការផ្សព្វផ្សាយ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប អំពីផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ព្រមទាំងបានដឹកនាំកំលាំងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យរកឃើញ និងបានធ្វើការកំទេចចោលនូវផលិតផលដែលខូចគុណភាព និងផលិតផលមួយចំនួនដែលមានប្រើសារជាតិគីមីហួសកំរិត ។

ប៉ុន្តែ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ ក៏នៅតែមានសកម្មភាពប្រើប្រាស់សារជាតិគីមី លើផលិតផលចំណីអាហារ និងទំនិញមួយចំនួនដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកកំពុងចរាចរ និងដាក់លក់នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។ អំពើទាំងនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ បើសិនជាការគ្រប់គ្រង និងវិធានការត្រួតពិនិត្យ ពុំត្រូវបានអនុវត្តឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាពនោះទេ។

ដើម្បីធ្វើការគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបការប្រើសារជាតិគីមីលើផលិតផលចំណីអាហារដែលកំពុងនាំចូល និងផលិតនៅតាមរោងចក្រ មូលដ្ឋានសិប្បកម្ម និងកំពុងចរាចរលើទីផ្សារ ក៏ដូចជាចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងតាមសាលារៀន ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាល ដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម :

១- គណៈកម្មាធិការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម ដែលដើរតួនាទីជាគណៈកម្មាធិការ Codex ជាតិផងនោះ ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ខិតខំពង្រឹងការអនុវត្តការងារតាមតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យគុណភាពផលិតផលជាប្រចាំលើទំនិញនាំចូល និងផលិតផលក្នុងស្រុក ដែលកំពុងផលិត និងកំពុងចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរខេត្ត ក្រុង ដោយត្រូវពង្រឹងនាយកដ្ឋានកាំកុងត្រូល ទីចាត់ការគយ និងរដ្ឋាករ និងកងកំលាំងប្រដាប់អាវុធតាមព្រំដែន ដើម្បីទប់ស្កាត់ការនាំចូលទំនិញដែលមានសារជាតិគីមី ទំនិញគេចពន្ធនៅតាមច្រករបៀងតាមព្រំដែន ព្រោះទំនិញគេចពន្ធទាំងនោះភាគច្រើនជាទំនិញដែលមានប្រើសារជាតិគីមីពុល ឬជាទំនិញខូចគុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ។

៣- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យ និងចុះយកសំណាក ដើម្បីយកមកពិសោធរកគុណភាពនៃផលិតផលនៅតាមរោងចក្រ សហគ្រាស សិប្បកម្មតាមខេត្ត ក្រុង ទូទាំងប្រទេសឱ្យបានជាប់ជាប្រចាំ ។

៤- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងសុខាភិបាល ដោយចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះទៅពិនិត្យកន្លែងលក់ដូរចំណីអាហារនៅតាមសាលារៀនទូទាំងប្រទេស ជាពិសេសសាលាបឋមសិក្សា និងខិតខំអនុវត្តតាមសារាចរណែនាំ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាកន្លងមក ដោយត្រូវពង្រីកនូវកម្មវិធីអប់រំអនាម័យ និងសុវត្ថិភាព ចំណីអាហារដល់គ្រូបង្រៀន សិស្ស និស្សិត ឱ្យបានគ្រប់ខេត្ត ក្រុង និងគួរបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅគ្រប់កំរិតសិក្សា។

៥- ក្រសួងសុខាភិបាល ត្រូវត្រួតពិនិត្យជាប្រចាំនៅតាមរោងចក្រ សហគ្រាសផលិតឱសថក្នុងប្រទេស គ្រប់គ្រងឱសថស្ថាន និងឱសថស្ថានរងទាំងអស់ ដើម្បីរកឱ្យឃើញនូវឱសថដែលក្លែងក្លាយ និងឱសថដែលហួសរយៈពេលប្រើប្រាស់ ។ ទន្ទឹមនេះ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់បញ្ជីអនុញ្ញាតឱ្យនាំចូលឱសថដល់សមត្ថកិច្ច ដែលត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែន ដើម្បីជួយទប់ស្កាត់ការនាំចូលឱសថខុសច្បាប់ ។

៦- ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល និងសមត្ថកិច្ចនៃក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្នុងការចុះត្រួតពិនិត្យម្ហូបអាហារនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន និងអាហារដ្ឋាននៅទូទាំងប្រទេស ដើម្បីធានាសុវត្ថិភាពចំណីអាហារជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ។

៧- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវខិតខំណែនាំផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងច្បាស់លាស់ដល់ប្រជាកសិករ អំពីរបៀបប្រើប្រាស់សារជាតិគីមី និងថ្នាំសំលាប់សត្វល្អិតទៅលើផលិតផលកសិកម្ម ដំណាំស្រូវ កសិដ្ឋានកន្លែងចិញ្ចឹមសត្វគ្រប់ប្រភេទ និងអនាម័យសត្តឃាតដ្ឋាន ។

៨- រាជបណ្ឌិតសភាកម្ពុជា ត្រូវសហការជាមួយក្រសួងព័ត៌មាន ក្នុងការដឹកនាំរៀបចំខ្លឹមសារ ដើម្បីធ្វើការផ្សព្វផ្សាយ អប់រំដល់សាធារណជន ស្តីពីសុវត្ថិភាពចំណីអាហារ តាមវិទ្យុ ទូរទស្សន៍ និងបណ្តាញព័ត៌មានឱ្យបានទូលំទូលាយ ដោយសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។

៩- ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវធ្វើបញ្ជីកំណត់អំពីសារធាតុគីមីណាដែលហាមឃាត់មិនឱ្យនាំចូល មិនឱ្យប្រើប្រាស់ ឬអនុញ្ញាតឱ្យនាំចូលតែមានកំរិត និងកំណត់អំពីសមត្ថកិច្ចដែលជាអ្នកអនុញ្ញាត ហើយត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ សរ.ណ

សារាចរ

ស្តីពី

ការគ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី

កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចេញនូវអនុក្រឹត្យ និងលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា ជាពិសេសផលិតផលចំណីអាហារដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកមួយចំនួន ដែលមានប្រើសារជាតិគីមី ដើម្បីក្លែងបន្លំគុណភាព ។ រាជរដ្ឋាភិបាល បានធ្វើការផ្សព្វផ្សាយដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប អំពីផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ព្រមទាំងបានដឹកនាំកំលាំងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យរកឃើញ និងបានធ្វើការកំទេចចោលនូវផលិតផលដែលខូចគុណភាព និងផលិតផលមួយចំនួនដែលមានប្រើសារជាតិគីមីហួសកំរិត ។

ប៉ុន្តែ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ ក៏នៅតែមានសកម្មភាពប្រើប្រាស់សារជាតិគីមី លើផលិតផលចំណីអាហារ និងទំនិញមួយចំនួនដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកកំពុងចរាចរ និងដាក់លក់នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។ អំពើទាំងនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ បើសិនជាការគ្រប់គ្រង និងវិធានការត្រួតពិនិត្យ ពុំត្រូវបានអនុវត្តឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាពនោះទេ។

ដើម្បីធ្វើការគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបការប្រើសារជាតិគីមីលើផលិតផលចំណីអាហារដែលកំពុងនាំចូល និងផលិតនៅតាមរោងចក្រ មូលដ្ឋានសិប្បកម្ម និងកំពុងចរាចរលើទីផ្សារ ក៏ដូចជាចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងតាមសាលារៀន ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាល ដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម :

១- គណៈកម្មាធិការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម ដែលដើរតួនាទីជាគណៈកម្មាធិការ Codex ជាតិផងនោះ ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ខិតខំពង្រឹងការអនុវត្តការងារតាមតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យគុណភាពផលិតផលជាប្រចាំលើទំនិញនាំចូល និងផលិតផលក្នុងស្រុក ដែលកំពុងផលិត និងកំពុងចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរខេត្ត ក្រុង ដោយត្រូវពង្រឹងនាយកដ្ឋានកាំកុងត្រូល ទីចាត់ការគយ និងរដ្ឋាករ និងកងកំលាំងប្រដាប់អាវុធតាមព្រំដែន ដើម្បីទប់ស្កាត់ការនាំចូលទំនិញដែលមានសារធាតុគីមី ទំនិញគេចពន្ធនៅតាមច្រករបៀងតាមព្រំដែន ព្រោះទំនិញគេចពន្ធទាំងនោះភាគច្រើនជាទំនិញដែលមានប្រើសារធាតុគីមីពុល ឬជាទំនិញខូចគុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ។

៣- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យ និងចុះយកសំណាក ដើម្បីយកមកពិសោធរកគុណភាពនៃផលិតផលនៅតាមរោងចក្រ សហគ្រាស សិប្បកម្មតាមខេត្ត ក្រុង ទូទាំងប្រទេសឱ្យបានជាប់ជាប្រចាំ ។

៤- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងសុខាភិបាល ដោយចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះទៅពិនិត្យកន្លែងលក់ដូរចំណីអាហារនៅតាមសាលារៀនទូទាំងប្រទេស ជាពិសេសសាលាបឋមសិក្សា និងខិតខំអនុវត្តតាមសារាចរណែនាំ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាកន្លងមក ដោយត្រូវពង្រីកនូវកម្មវិធីអប់រំអនាម័យ និងសុវត្ថិភាព ចំណីអាហារដល់គ្រូបង្រៀន សិស្ស និស្សិត ឱ្យបានគ្រប់ខេត្ត ក្រុង និងគួរបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅគ្រប់កំរិតសិក្សា។

៥- ក្រសួងសុខាភិបាល ត្រូវត្រួតពិនិត្យជាប្រចាំនៅតាមរោងចក្រ សហគ្រាសផលិតឱសថក្នុងប្រទេស គ្រប់គ្រងឱសថស្ថាន និងឱសថស្ថានរងទាំងអស់ ដើម្បីរកឱ្យឃើញនូវឱសថដែលក្លែងក្លាយ និងឱសថដែលហួសរយៈពេលប្រើប្រាស់ ។ ទន្ទឹមនេះ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់បញ្ជីអនុញ្ញាតឱ្យនាំចូលឱសថដល់សមត្ថកិច្ច ដែលត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែន ដើម្បីជួយទប់ស្កាត់ការនាំចូលឱសថខុសច្បាប់ ។

៦- ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល និងសមត្ថកិច្ចនៃក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្នុងការចុះត្រួតពិនិត្យម្ហូបអាហារនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន និងអាហារដ្ឋាននៅទូទាំងប្រទេស ដើម្បីធានាសុវត្ថិភាពចំណីអាហារជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ។

៧- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវខិតខំណែនាំផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងច្បាស់លាស់ដល់ប្រជាកសិករ អំពីរបៀបប្រើប្រាស់សារធាតុគីមី និងថ្នាំសំលាប់សត្វល្អិតទៅលើផលិតផលកសិកម្ម ដំណាំស្រូវ កសិដ្ឋានកន្លែងចិញ្ចឹមសត្វគ្រប់ប្រភេទ និងអនាម័យសត្តឃាតដ្ឋាន ។

៨- រាជបណ្ឌិតសភាកម្ពុជា ត្រូវសហការជាមួយក្រសួងព័ត៌មាន ក្នុងការដឹកនាំរៀបចំខ្លឹមសារ ដើម្បីធ្វើការផ្សព្វផ្សាយ អប់រំដល់សាធារណជន ស្តីពីសុវត្ថិភាពចំណីអាហារ តាមវិទ្យុ ទូរទស្សន៍ និងបណ្តាញព័ត៌មានឱ្យបានទូលំទូលាយ ដោយសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។

៩- ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវធ្វើបញ្ជីកំណត់អំពីសារធាតុគីមីណាដែលហាមឃាត់មិនឱ្យនាំចូល មិនឱ្យប្រើប្រាស់ ឬអនុញ្ញាតឱ្យនាំចូលតែមានកំរិត និងកំណត់អំពីសមត្ថកិច្ចដែលជាអ្នកអនុញ្ញាត ហើយត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល)

និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ទីចាត់ការគយ និងរដ្ឋាករ) ដែលទទួលភារកិច្ចត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និងចម្លង មកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ។

១០- ក្រសួង ស្ថាប័ន ត្រូវពង្រឹងការងារអភិបាលកិច្ចល្អដល់មន្ត្រីរាជការក្រោមឱវាទ ឱ្យខិតខំផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងផ្នែកឯកជនឱ្យកាន់តែប្រសើរឡើង ជាពិសេសមន្ត្រីភ្នាក់ងារត្រួតពិនិត្យគុណភាពផលិតផល ដែលផលិតក្នុងរោងចក្រ សិប្បកម្ម សហគ្រាស កសិដ្ឋាន និងទំនិញដែលកំពុងចរាចរលើទីផ្សារ ព្រមទាំងនៅច្រកទ្វារព្រំដែន ដោយបង្កើនការផ្សព្វផ្សាយអប់រំ ដើម្បីឱ្យអ្នកផលិត និងអ្នកប្រើប្រាស់កាន់តែមានការយល់ដឹងពីផលប៉ះពាល់ដល់សុខភាព ។

ទទួលបាននូវសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤៩ សរណន

សារាចរណែនាំ

ស្តីពី

ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦

I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៦

១- ក្នុងឆ្នាំ ២០០៤ កន្លងទៅនេះ ទោះបីជាមានឥទ្ធិពលអវិជ្ជមានខាងក្នុង និង ពីក្រៅមួយចំនួន ដូចជា ការជាប់គាំងខាងនយោបាយ គ្រោះរាំងស្ងួត ការឡើងថ្លៃប្រេងឥន្ធនៈ អំពើភេរវកម្ម ជម្ងឺឧត្បាត យ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនមួយដ៏ខ្ពស់គឺប្រមាណ ៧,៧% ក្នុងថ្លៃថេរ លើសពីការគ្រោងទុក ៥,៨% ក្នុងច្បាប់ហិរញ្ញវត្ថុ ។ វិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និង សកម្មភាពសំណង់ដែលបន្តកើនឡើង និង រីកដុះដាលជាលំដាប់ គឺជាកត្តាសំខាន់ក្នុងការជំរុញដល់កំណើននេះ ។ លទ្ធផលនេះក៏បានមកផងដែរ ដោយសាររាជរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ។ អំណោយផលនៃកត្តាខាងក្រៅ ពិសេសគឺការបន្តជួយគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ក៏បានរួមចំណែកក្នុងការជំរុញកំណើននេះផងដែរ ។ ទោះជានៅក្នុងបរិការណ៍មួយដែលកម្ពុជាសម្រេចបាននូវកំណើនខ្ពស់ក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែធានាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ពិសេស រក្សាបាននូវអត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រឹម ៣,៩% គឺទាបជាងគោលដៅដែលបានគ្រោងពីដើមឆ្នាំក្នុងអត្រា ៥% ។ រីឯអត្រាប្តូរប្រាក់មានស្ថិរភាព និយាយជារួម ហើយទុនបំរុងធានាបានសំរាប់ការនាំចូល ៣ ខែ ជាប្រចាំ ។

២- ក្នុងឆ្នាំ ២០០៥ នេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចនឹងសម្រេចបានចំនួន ៦,៣% ដោយសង្ឃឹមថា វិស័យកសិកម្មនឹងកើនឡើងចំនួន ៤,៧% ដែលក្នុងនោះ ផលិតផលស្រូវ និង កសិផល នឹងកើនឡើង ៥,៥% វិស័យឧស្សាហកម្មនឹងកើនឡើងចំនួន ៤,៧% ចំនួនភ្ញៀវទេសចរនឹងកើនឡើង ៣០% សកម្មភាពសាងសង់នឹងកើនឡើង ១៦% ហើយវិស័យសេវាកម្មនឹងកើនឡើង ៧,៨% ។ ប៉ុន្តែការនាំចេញសំលៀកបំពាក់នឹងកើនឡើងប្រមាណតែ ២% ប៉ុណ្ណោះ ។ ជាសរុប ការនាំចេញនឹងកើនឡើងចំនួន ២៣,៤% ហើយការនាំចូលនឹងកើនឡើង ២៤,៦% ។ ដោយសារវិធានការណ៍របស់រាជរដ្ឋាភិបាល ដែលប្រកាន់យកជំហការងារតាម

អតិក្រមសកម្មគ្រប់គ្រង ស្ថានភាពរូបិយវត្ថុក្នុងឆ្នាំ ២០០៥ នេះ នឹងឆ្លុះបញ្ចាំងផងដែរនូវស្ថានភាពសារពើពន្ធមួយដែលមានលក្ខណៈល្អសំរាប់ជំរុញកំណើន និង ការអភិវឌ្ឍន៍ ។ ទុនបម្រុងអន្តរជាតិជារូបិយវត្ថុបរទេស ក៏នឹងបន្តធានាការនាំចូលប្រមាណបាន ៣ ខែ ដែរ ។ អត្រាប្តូរប្រាក់នឹងបន្តរក្សាអោយមានស្ថិរភាព គឺជាមធ្យមភាគក្នុងរង្វង់ប្រមាណ ៤.០៥០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

៣- ផ្នែកលើស្ថានភាពគួរអោយលើកទឹកចិត្តនៃសេដ្ឋកិច្ចជាតិនេះ ជាពិសេសលទ្ធផលនៃការអនុវត្តនីតិវិធានការកែលំអអភិបាលកិច្ចក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលក្នុងត្រីមាសទី ១ ឆ្នាំ ២០០៥ នេះ សម្រេចបានលទ្ធផលគួរកត់សម្គាល់ ជាពិសេស នាយកដ្ឋានពន្ធដារប្រមូលចំណូលបានចំនួន ១៥៥ ពាន់លានរៀល គឺស្មើនឹង ១២៧% នៃការគ្រោងទុក ហើយទីចាត់ការគយនិងរដ្ឋាករប្រមូលចំណូលបានជិត ៣៦៦ ពាន់លានរៀល គឺជិតស្មើនឹង ១១១% នៃការគ្រោងទុក ។ រាជរដ្ឋាភិបាលសង្ឃឹមថា ការអនុវត្តថវិកាក្នុងឆ្នាំ ២០០៥ នេះ អាចនឹងសម្រេចបានតាមគោលដៅដែលច្បាប់ហិរញ្ញវត្ថុបានកំណត់ ។ ចំណូលថវិកាក្នុងស្រុកអាចនឹងសម្រេចបានចំនួន ១១,៣៨% នៃផសស ធៀបនឹងឆ្នាំ ២០០៤ ដែលសម្រេចបានត្រឹម ១១,២៥% នៃផសស ក្នុងខណៈដែលចំណាយសរុបអាចនឹងសម្រេចបានចំនួន ១៦,៨០% នៃផសស ធៀបនឹងឆ្នាំ ២០០៤ ដែលសម្រេចបានត្រឹម ១៥,៨៧% នៃផសស ហើយក្នុងនោះ ចំណាយចរន្តអាចនឹងសម្រេចបាន ៩,៩០% ដែលអាចធានាបាននូវអតិរេកចរន្តចំនួន ១,៤០% សម្រាប់ប្រើប្រាស់ក្នុងការវិនិយោគ ។ ចំណាយមូលធនសរុបនៃថវិកាអាចនឹងសម្រេចបាន ៦,៩០% នៃផសស នៅក្នុងឆ្នាំ ២០០៥ នេះ ។

៤- ក្នុងឆ្នាំ ២០០៦ កំណើនសេដ្ឋកិច្ចនឹងសម្រេចបានចំនួន ៦,១% ។ ការព្យាករណ៍នេះឈរលើសេណារីយ៉ូសុទិដ្ឋិនិយមដោយសង្ឃឹមថា ការនាំចេញសម្លៀកបំពាក់នឹងកើនឡើងដល់ចំនួន 10% ចំនួនភ្ញៀវទេសចរនឹងកើនឡើង ៣៥% សកម្មភាពសាងសង់នឹងកើនឡើង ២៥% ផលិតផលកសិកម្មនឹងកើនឡើងចំនួន ៧% ។ អត្រាអតិផរណានឹងត្រូវបានគ្រប់គ្រងអោយស្ថិតក្នុងកម្រិតប្រមាណ ៣% ។ ការព្យាករណ៍សំរាប់រយៈពេលមធ្យម (២០០៥-២០០៨) គឺសេដ្ឋកិច្ចនឹងមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៦% ស្របតាមគោលដៅកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ទោះបីជាការបញ្ចប់នៃប្រព័ន្ធកូតាអាចធ្វើឱ្យកំណើនវិស័យឧស្សាហកម្មកាត់ដេរធ្លាក់ចុះវិញខ្លះក៏ដោយ ។ រាជរដ្ឋាភិបាលនឹងខិតខំបន្តជំរុញបន្ថែមទៀត លើការអភិវឌ្ឍន៍វិស័យទេសចរណ៍ សកម្មភាពសំណង់ និង សេវាកម្ម ដើម្បីរក្សាអោយមានកំណើនប្រកបដោយចីរភាព ទន្ទឹមនឹងពិពិធកម្មសេដ្ឋកិច្ចពិសេសជំរុញវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ។ នៅក្នុងឆ្នាំ ២០០៦ នេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយ័ត្ន ត្រូវផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចមួយខ្ពស់ដូចបានកំណត់ខាងលើនេះ ។ រាជរដ្ឋាភិបាល ប្តេជ្ញាបន្តរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចអោយនៅតែត់មត់ល្អ ពិសេសគ្រប់គ្រងអត្រាអតិផរណាអោយស្ថិតក្នុងកំរិតជាមធ្យមប្រមាណ ៣% ក្នុងមួយឆ្នាំ និង រក្សាអោយបានជារួមនូវលំនឹងនៃអត្រាប្តូរប្រាក់ ។

៥- ពិតណាស់ថា ទោះបីជាកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមួយយ៉ាងខ្ពស់ ហើយបានខិតខំអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីកំណែទម្រង់គ្រប់វិស័យក៏ដោយ ជារួម អត្រានៃភាពក្រីក្រនៅតែមានកម្រិតខ្ពស់នៅឡើយ ដោយសារមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចមានលក្ខណៈតូចចង្អៀត ដែលពឹងផ្អែកជាសំខាន់លើកត្តាក្រៅប្រទេស ពិសេសលើការនាំចេញឧស្សាហកម្មកាត់ដេរ និង វិស័យទេសចរណ៍ ។ ដូច្នេះ ដើម្បីធានាបាននូវការចែករំលែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ដែលនឹងផ្តល់ផលជាវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រសមស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តអនុវត្តឱ្យបានសម្រេចជោគជ័យនូវ ***«យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** ដែលមានអភិបាលកិច្ចល្អជាស្នូល ដោយផ្តោតលើយុទ្ធសាស្ត្របួនយ៉ាងគឺ៖

ទី១: ជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម

ទី២: ជំរុញការអភិវឌ្ឍវិស័យឯកជន និង បង្កើនការងារ

ទី៣: បន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង

ទី៤: បន្តជំរុញការកសាងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍន៍ធនធានមនុស្ស ។

៦- នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ ក្នុងរយៈពេលខ្លីចំពោះមុខ រាជរដ្ឋាភិបាលនឹងបន្តប្រមូលផ្តុំលើកម្មវិធីកំណែទំរង់សំខាន់ៗ ដូចតទៅ÷

ក. បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចត្រឹមត្រូវ និង ប្រុងប្រយ័ត្ន ដើម្បីជាបរិស្ថានសំរាប់សម្រេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចិរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាទាប ។

ខ. បន្តអនុវត្តនូវកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ដែលសំដៅធានានូវភាពទុកចិត្តបាននៃថវិកាជាតិ តាមរយៈការខិតខំបង្កើនចំណូល ការធ្វើចារណកម្មចំណាយ ដោយផ្តោតជាពិសេសលើវិធានការពង្រឹងអភិបាលកិច្ចល្អ និង បង្កើនប្រសិទ្ធភាពរបស់រដ្ឋក្នុងការផ្តល់សេវា និង វិធានការកាត់បន្ថយបំណុលជាសាច់ប្រាក់ ដែលរដ្ឋជំពាក់អ្នកផ្គត់ផ្គង់ឯកជន ។

គ. បន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសលើកស្ទួយវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម និង ជួយគាំទ្រសហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការសម្រួលពាណិជ្ជកម្មតាមរយៈការបង្កើតបញ្ជរតែមួយ និង ជំរុញផ្នែកឯកជនអោយចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមានច្បាប់សម្បទានធានា ក្នុងខណៈដែលរាជរដ្ឋាភិបាលខ្លួនឯងបាន និង កំពុងខិតខំកសាងដោយផ្ទាល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ ប្រការទាំងនេះទាមទារការពង្រឹងអភិបាលកិច្ចល្អ ពិសេសវិធានការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍កម្មវិធីសកម្មភាពកំណែទំរង់ច្បាប់ និង តុលាការ ការពង្រឹងនីតិរដ្ឋ និង ការកែលំអទីផ្សារពលកម្ម ។

ឃ. បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្របតាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំពេញគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។

៥. បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

៦. កសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និង បំពេញកាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញប្រយោជន៍ពីសមាជិកភាពនេះ អោយបានជាអតិបរមា ។

៧.បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ពិសេសធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និង ពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបម្រើឱ្យគោលការណ៍ «រដ្ឋបាលឯកភាព» ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ និង អនុវត្តផែនការបង្កើនប្រសិទ្ធិភាព នៃការផ្ទេរ និង ការផ្តល់ថវិកាជូនមូលនិធិឃុំ-សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសិក្សាដើម្បីដាក់ឱ្យអនុវត្តសាកល្បងនូវការប្រមូលចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសគឺពន្ធប៉ាតង់ និង ពន្ធលើមធ្យោបាយដឹកជញ្ជូននៅរាជធានីភ្នំពេញ និង នៅក្រុងព្រះសីហនុ តែត្រូវស្ថិតក្នុងក្របខ័ណ្ឌច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ។

៨. បន្តជម្រុញការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការពង្រីកការអនុវត្តន៍កន្សោមអាទិភាព និង កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារ ។

៧- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៦ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៥ នេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៥ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះហើយផ្ញើរជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ ២០០៥ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើរជូនស្ថាប័ននីតិបញ្ញត្តិ អោយបានក្នុងសប្តាហ៍ទី១ នៃខែ វិច្ឆិកា ២០០៥ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ ក្នុងការពិនិត្យ ពិភាក្សា និង អនុមតិសេចក្តីព្រាងនេះបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០០៥ ។

II- ក្របខ័ណ្ឌថវិកាជាតិឆ្នាំ ២០០៦

២-១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០០៦

៨- លទ្ធផលអនុវត្តឆ្នាំ ២០០៤ និង ការព្យាករណ៍រយៈពេលមធ្យម បង្ហាញឱ្យឃើញថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០០៦ នឹងមានលក្ខណៈប្រហាក់ប្រហែលដូចឆ្នាំ ២០០៥ ដែរ ហើយសូចនាករម៉ាក្រូសំខាន់ៗ នឹងអាចសម្រេចបានដូចខាងក្រោម ÷

- កំណើនសេដ្ឋកិច្ចតាមថ្លៃថេរ នឹងមានចំនួនប្រមាណ ៦,១% ដែលធ្វើឱ្យផលិតផលសរុបក្នុងស្រុក (ផសស) សំរេចបានប្រមាណ ២៨.២៧១ ពាន់លានរៀល ។
- អតិផរណានឹងស្ថិតក្នុងកម្រិតប្រមាណ ៣,៥% ដែលត្រូវអោយមានការបន្តអនុវត្តន៍គោលនយោបាយសារពើពន្ធប្រកបដោយភាពមោះមុត និង ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ។
- អត្រាប្តូរប្រាក់រៀល- ដុល្លារជាមធ្យមនឹងស្ថិតក្នុងកំរិត ៤.០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ។
- និនភាពគណនីចរន្ត នឹងថយចុះពី ១១% នៃ ផសស ក្នុងឆ្នាំ ២០០៥ ទៅ ១០.៣% នៃ ផសស ក្នុងឆ្នាំ ២០០៦ ។
- ទុនបម្រុងអន្តរជាតិសរុប នឹងបន្តធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយបណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដាន និង វាយតម្លៃជាប្រចាំលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ដើម្បីជាមូលដ្ឋានសំរាប់ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុ ជាពិសេសការត្រួតពិនិត្យពាក់កណ្តាលឆ្នាំ ។

២-២. បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៦

៩- បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួន នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ផង ។ បញ្ហាប្រឈមទាំងអស់នោះ រួមមានដូចខាងក្រោម ÷

ទី១- ការធានាអោយបាននូវការគោរពវិន័យថវិកាយ៉ាងខ្ជាប់ខ្ជួន សំដៅកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

ទី២- ការរៀបចំកម្មវិធីចំណូល ចំណាយអោយបានច្បាស់លាស់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ដោយអនុវត្តយ៉ាងហ្មឹងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសចៀសវាងនូវការផ្ទេរឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើនហួសទៅបង្គរនៅរតនាគារជាតិ ដែលជាប្រការធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

ទី៣- បន្តពង្រឹងការគ្រប់គ្រងបំណុល ដោយបន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវការខ្ចីតែឥណទានដែលមានលក្ខណៈសម្បទាន ។

ទី៤- បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេសចំពោះវិស័យអាទិភាពទាំងបួនរួមមាន អប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ និង ចំណាយវិនិយោគលើប្រព័ន្ធហេដ្ឋា

រចនាសម្ព័ន្ធរូបវន្ត មានផ្លូវ- ស្ពាន និងជាពិសេសចំណាយវិនិយោគលើប្រព័ន្ធស្រោចស្រព ដែលជាអាទិភាពខ្ពស់ជុតរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភា ។

២-៣. គំរោងចំណូល-ចំណាយថវិកាឆ្នាំ ២០០៦

ក-គំរោងចំណូលថវិកាក្នុងស្រុក

១០- តាមការវិភាគ និង ព្យាករណ៍លើស្ថានភាពជាក់ស្តែង ចំណូលថវិកាក្នុងស្រុកក្នុងឆ្នាំ ២០០៥ អាចនឹងសម្រេចបានក្នុងរង្វង់ប្រមាណ ១១,៣៨% នៃផសស ហើយចំណាយសរុបអាចនឹងអនុវត្តបានក្នុងកំរិត ១៦,៨០% នៃផសស ។ លើមូលដ្ឋាននេះ និង ផ្អែកលើការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកំណត់គោលដៅចំណូលថវិកាក្នុងស្រុកសម្រាប់ឆ្នាំ ២០០៦ អោយសម្រេចបានប្រមាណ ១២% នៃផសស ដែលក្នុងនោះ ចំណូលចរន្តត្រូវសម្រេចបាន ១១,៨១% នៃផសស រួមមានចំណូលសារពើពន្ធ ៩,១៧% នៃផសស និង ចំណូលមិនមែនសារពើពន្ធ ២,៦៤% នៃផសស ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកំណត់គោលដៅចំណាយសរុបសំរាប់ឆ្នាំ ២០០៦ អោយសម្រេចបានដល់ ១៧,៥០% នៃផសស ។

១១- ដោយផ្អែកលើតម្រូវការចំណាយ និង គោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដូចមានចែងខាងលើនេះ រាជរដ្ឋាភិបាលត្រូវបន្តអនុវត្តបណ្តាវិធានការហ្មឹងម៉ាត់ទាំងឡាយ ក្នុងការកែទម្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាពិសេសក្នុងការកៀងគរចំណូល ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម ÷

ទី១- ផ្នែកចំណូលពន្ធដារ:

- បន្តការពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ការធ្វើសវនកម្មពន្ធ និង ការកែលំអរចនាសម្ព័ន្ធចាត់តាំង និង គ្រប់គ្រងស្ថាប័ន ជាពិសេសការពង្រីកមូលដ្ឋានយកពន្ធ ដោយធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត និង ពង្រឹងរដ្ឋបាលពន្ធដារ ។

- អនុវត្តនូវកម្មវិធីកែលំអរចនាសម្ព័ន្ធ តាមរយៈការអនុវត្តន៍នូវប្រព័ន្ធគ្រប់គ្រងតាមបែបអន្តរជាតិ ចំពោះរាល់តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ។

- កសាង និង អនុវត្ត នូវផែនការយុទ្ធសាស្រ្តបច្ចេកវិទ្យាពត៌មាន ជាពិសេសខាងផ្នែកប្រមូលពន្ធ ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- អនុម័ត នូវអនុក្រឹត្យសម្រាប់អនុវត្តច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

- អនុវត្តទាំងស្រុង និង ឱ្យបានហ្មឹងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- ធ្វើការកែប្រែអនុក្រឹត្យពន្ធលើតំលៃបន្ថែម (VAT) ដើម្បីពង្រីកមូលដ្ឋានប្រមូលពន្ធតាមរបបពិត ។

- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។

- ពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេងកាត ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលជាអតិបរិមាពីវិស័យនេះ តាមរយៈការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ។

- ធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

ទី២- <u>ផ្នែកចំណូលពន្ធគយ:</u>

- ជំរុញការអនុម័តច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់នេះ ។

- បន្តកែលំអរនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- ចាប់ផ្តើមអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និង រដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលថវិកា រួមមាន៖

*ក.*វិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរ រត់ពន្ធត្រូវតែបង្ហាញឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត នូវជវភាពនៃការងាររបស់ខ្លួនក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើររត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខាអេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ.*សហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរពត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ.*លើកឡើង និង អនុវត្តនូវវិធានការច្បាស់លាស់ តែទន់ភ្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តការពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីគយ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន

ពិសេសគឺត្រូវរៀបចំឱ្យបានសម្រេច ហើយដាក់ឱ្យអនុវត្តសាកល្បងនៅខែ កុម្ភៈ ២០០៦ នូវប្រព័ន្ធបញ្ជរតែមួយ (Single Window) សម្រាប់ត្រួតពិនិត្យការនាំចេញ និង នាំចូល នៅតាមច្រកព្រំដែនមួយចំនួន ពិសេសត្រូវចាប់ផ្តើមនៅកំពង់ផែក្រុងព្រះសីហនុ ។

- ពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅទីងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

ទី៣- ចំណូលមិនមែនសារពើពន្ធ:

- រៀបចំ និង ជម្រុញឱ្យនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ បំពេញមុខងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព និង ភាពសក្តិសិទ្ធិ ។

- អនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធចំណូលមិនមែនសារពើពន្ធ ហើយដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- ត្រៀមរៀបចំបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានរួចរាល់ និង អនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាព ។

- ក្រសួង ស្ថាប័នទាំងអស់ ត្រូវប្រគល់ឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរាល់កិច្ចសន្យាទាំងអស់ដែលពាក់ព័ន្ធនឹងសម្បទាន ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើសវនកម្មលើកិច្ចសន្យាធំជាងគេចំនួន ៥ ដើម្បីធានាការពារផលប្រយោជន៍រដ្ឋ និង ពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាទាំងអស់នេះ ។

- បញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ លើកលែងតែសារពើភ័ណ្ឌដីរដ្ឋ ដែលត្រូវបន្តអនុវត្តនៅក្នុងរយៈពេលវែងខាងមុខ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់ បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

ខ- គម្រោងចំណាយថវិកា

១២- ដើម្បីសម្រេចបាននូវគោលដៅដែលបានគូសបញ្ជាក់ខាងលើ គម្រោងចំណាយថវិកាឆ្នាំ ២០០៦ នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើបណ្តាមូលដ្ឋានជាយុទ្ធសាស្ត្រដូចខាងក្រោម÷

• ត្រូវបន្តរឹតត្បិតចំណាយសរុបឱ្យស្ថិតក្នុងកំរិត ១៧,៥០% នៃផសស ក្នុងនោះ ចំណាយមូលធនប្រមាណ ៧,៣០ % នៃផសស ។ ឯចំណាយចរន្តត្រូវស្ថិតក្នុងរង្វង់ ១០,២០% នៃផសស ដើម្បីធានាអតិរេកចរន្តអោយបាន ១,៦១% នៃផសស សំរាប់វិនិយោគ ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,៨៦% នៃផសស ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,៩១% នៃផសស ។ ទន្ទឹមនឹងនេះ បង្កើនចំណាយសំរាប់វិលសំណុលដល់ចំនួន ០,៥៣% នៃផសស ។

• ត្រូវបន្តកៀងគរជំនួយផ្លូវការពីបរទេសសំរាប់ការវិនិយោគ (រួមទាំងជំនួយឥតសំណងផង) ដើម្បីទប់ទល់ឱនភាពថវិកាសរុបឱ្យនៅត្រឹម -៥,៥% នៃផសស ។

• ត្រូវបែងចែកចំណាយចរន្តទៅតាមវិស័យនីមួយៗដូចតទៅៈ រដ្ឋបាលទូទៅ ១,៣៦% នៃផសស ផ្នែកសន្តិសុខ និង យោធា ២,០៥% នៃផសស វិស័យសេដ្ឋកិច្ច ១,០៩% នៃផសស និង សង្គមកិច្ចស្មើនឹង ៣,៦៧% នៃផសស ។

១៣- ថវិកាឆ្នាំ ២០០៦ ខាងមុខនេះ ត្រូវបំពេញគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចឱ្យការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៦ នឹងផ្តល់ការបែងចែកជាក់ស្តែងទៅតាមវិស័យជាអាទិភាពទាំងនេះ ដូចខាងក្រោម ÷

• បង្កើនថវិកាសំរាប់វិស័យសុខាភិបាលចំនួន ១៤,៣% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ដើម្បីសម្រេចឱ្យបាននូវសមាមាត្រ ១២,៧៤% នៃចំណាយចរន្តថវិការដ្ឋ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យសុខាភិបាលឆ្នាំ ២០០៦ ។

• បង្កើនថវិកាសំរាប់វិស័យអប់រំចំនួន ២២% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ដើម្បីសម្រេចឱ្យបាននូវសមាមាត្រ ១៨,៤៥% នៃចំណាយចរន្តថវិការដ្ឋ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំឆ្នាំ ២០០៦ ។

• បង្កើនថវិកាសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ការអភិវឌ្ឍន៍កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ប្រមាណ ៣២% ធៀបទៅនឹងថវិកាឆ្នាំ ២០០៥ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ច ដើម្បីកំណើន និង កាត់បន្ថយភាពក្រីក្រ ។

• បង្កើនមូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ ២០០៦ ឱ្យដល់ ៧០ ពាន់លានរៀល (២.៥៤% នៃចំណូលចរន្តថវិការដ្ឋ) ។

III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៦

ក- ការគ្រោងគិតចំណូលថវិកាឆ្នាំ ២០០៦

១៤- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តា

លក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រាមូលដ្ឋានប្រមូលពន្ធ និង ការបង្កើតពន្ធថ្មី
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាលពន្ធដាររដ្ឋបាលគយ គោលនយោបាយពន្ធដារ និង គយ និង ការធ្វើវិចារណៈកម្មសារពើពន្ធ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាផ្តល់សេវាកម្ម និង ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួរលេខស្ថិតិដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និងការ-អភិវឌ្ឍន៍សេដ្ឋកិច្ច ។

ខ-ការគ្រោងគិតចំណាយថវិកាឆ្នាំ ២០០៦

១៥- ការគ្រោងគិតឥណទានថវិកាចំណាយ ត្រូវផ្តើមចេញពីតម្រូវការជាក់ស្តែង និង ដោយផ្ទាល់ដោយផ្អែកទៅលើកត្តាដែលទាក់ទងនឹងចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការ-ផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយដែលបានកំណត់កន្លងមក ដូចជា ចំណាយបេសកកម្មចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។

១៦- ជាទូទៅ គម្រោងចំណាយទាំងអស់សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវតែមានការវិភាគយ៉ាងល្អិតល្អន់ និង មានលិខិតយុត្តិការភ្ជាប់មកជាមួយ ដើម្បីពន្យល់តាមជំពូក តាមប្រការ ទៅតាមតារាងគំរូដូចបានធ្លាប់ធ្វើកន្លងមកសម្រាប់ធ្វើជាមូលដ្ឋាននៃការពិភាក្សា ។ ដោយឡែក ចំពោះថវិកាជំពូក ១១ ដែលជាជំពូកប្រមូលផ្តុំលើចំណាយសំភារៈ និង ការគ្រប់គ្រងរដ្ឋបាលចាំបាច់សម្រាប់ដំណើរការរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែមានភ្ជាប់មកជាមួយនូវលិខិតយុត្តិការស្របច្បាប់ ដើម្បីឱ្យឃើញនូវមូល-ហេតុនៃតម្រូវការជាក់ស្តែងរបស់បណ្តានាយកដ្ឋាន និង អង្គភាពនៅក្រោមឱវាទ ។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៥ ចំណាយប្រភេទនេះ ត្រូវតែកាត់បន្ថយចំនួន ៧% ដើម្បីបង្ហាញឱ្យឃើញអំពីភាពហ្មឹងម៉ាត់របស់រាជ-រដ្ឋាភិបាលក្នុងការសន្សំសំចៃថវិកា ទុកសម្រាប់ដោះរំលស់បំណុលសាច់ប្រាក់កក្ស័ះនៅធនាគារជាតិ និង សម្រាប់បង្កើនចំណាយវិនិយោគសាធារណៈ និង ចំណាយលើការថែទាំ និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តពិសេសផ្លូវ ស្ពាន និង ប្រព័ន្ធស្រោចស្រព ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៦

១៧- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកាសម្រាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ និង គោលនយោបាយថវិកា ហើយដែលកញ្ចប់ថវិកាឆ្នាំ ២០០៦ នេះមិនមានការប្រែប្រួលច្រើនឡើយ បើប្រៀបធៀបនឹងកញ្ចប់ថវិកាឆ្នាំ ២០០៥ ។ ជារួម ចំណាយចរន្តនៃថវិកាឆ្នាំ ២០០៦ ត្រូវបានបែងចែកតាមគោលដៅដូចខាងក្រោម ÷

- ការបង្កើនចំណាយសម្រាប់ពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ក្នុងគោលដៅជម្រុញការអភិវឌ្ឍន៍មូលដ្ឋាន
- ការបង្កើនចំណាយសម្រាប់ក្រសួងអាទិភាពទាំងបួន និង ធនធានទឹក
- ការត្រៀមឥណទានថវិកាសម្រាប់សងបំណុលសំខាន់ៗមួយចំនួន ។

១៨- ដូច្នេះ កញ្ចប់ថវិកានេះ គឺជាលទ្ធភាពថវិកាខ្ពស់បំផុតនៃគម្រោងចំណាយចរន្ត សម្រាប់ផ្តល់ជូនក្រសួង ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត- ក្រុងនីមួយៗ ,ធ្វើការបែងចែកលម្អិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ នៃមាតិកាថវិកា និង ដោយផ្អែកលើកម្មវិធីសកម្មភាព និង ផ្នែកអាទិភាពរបស់ខ្លួនសម្រាប់ឆ្នាំ ២០០៦ ដើម្បីឱ្យបានស្របតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៦ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត- ក្រុងទេ ។

១៩- ប្រការសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ក្នុងការបែងចែកកញ្ចប់ថវិកាឆ្នាំ ២០០៦ នេះ មានដូចតទៅ ÷

ក- ចំណាយបៀវត្ស ត្រូវគ្រោងគិតទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៥ ។ ចំនួនមន្ត្រីរាជការដែលលើស ត្រូវមានសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដោយផ្អែកតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែកនៅក្នុងថវិកាសរុបនៅក្នុងជំពូក ១០ ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង មិនត្រូវគិតនូវអតិផរណានៅក្នុងចំណាយថវិកាជំពូក ១០ នេះទេ ។ ចំពោះបុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។ នៅឆ្នាំ ២០០៦ ខាងមុខនេះ រាជរដ្ឋាភិបាលនឹងបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ១៥ ភាគរយ ដែលនឹងប្រើឥណទាននៃមូលនិធិបម្រុង ។

ខ- ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ និង ការជួសជុលតូច ត្រូវតែគ្រោងទុកប្រកបដោយលក្ខណៈស្និតស្បៀត សន្សំសំចៃ និង ត្រូវពឹងផ្អែកទៅតាមកម្មវិធីសកម្មភាព និង ធម្មនិយាមដូចមានចែងខាង

លើ ដើម្បីតម្រឹមឱ្យនៅក្នុងកញ្ចប់ថវិកានេះ ។ ត្រូវយកចិត្តទុកដាក់តិតតួរសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ ដើម្បីគ្រប់គ្រងចំណាយទាំងនេះនៅក្នុងល័ក្ខខ័ណ្ឌសន្សំសំចៃបំផុត ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកា ដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយទិញ ទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។

ត- កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះ ចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលា ដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយអគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោមៈ

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើបាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខស្ថាប័ននិតិបញ្ញត្តិ ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសនីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើការទូទាត់ថ្លៃប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដោយត្រង់ ទៅអ្នកផ្គត់ផ្គង់ ដោយផ្អែកលើវិក័យប័ត្រប្រើប្រាស់ជាក់ស្តែងប្រចាំខែ ដែលចេញ ដោយអ្នកផ្គត់ផ្គង់ និង ក្រោយពីត្រូវបានផ្ទៀងផ្ទាត់ និង ការឯកភាពទទួលស្គាល់ដោយក្រសួង ស្ថាប័ន ដែលបានប្រើប្រាស់ ។ ក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងធ្វើការទូទាត់នៅក្នុងខែមករា ២០០៦ តែវិក័យប័ត្រប្រើប្រាស់ប្រចាំខែ ធ្នូ ២០០៥ និង វិក័យប័ត្រប្រើប្រាស់ប្រចាំខែពីខែមករា ដល់ ខែ វិច្ឆិកា ២០០៦ ។ រីឯវិក័យប័ត្រប្រើប្រាស់ក្នុងខែធ្នូ ២០០៦ នឹងធ្វើការទូទាត់នៅក្នុងខែមករា ឆ្នាំ ២០០៧ ។ ចំពោះបំណុលមុនខែធ្នូ ២០០៥ ក្រសួងស្ថាប័នទាំងអស់ត្រូវទទួលទូទាត់ជំរះបញ្ជីរៀងៗខ្លួន ដោយប្រើឥណទានជំពូក ១១ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រង ការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីជូនឱ្យប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច ហើយដាក់ឱ្យគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។ ដោយឡែក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងវិសោធនកម្មលើអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និង អង្គភាពសាធារណៈរដ្ឋបាល និង អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ដើម្បីគ្រប់គ្រងតាមការណែនាំនេះ ។

- ក្នុងខណៈដែលប្រេងឥន្ធនៈកំពុងឡើងថ្លៃ តំរោងចំណាយប្រេងឥន្ធនៈសំរាប់ឆ្នាំ ២០០៦ ត្រូវកាត់បន្ថយចំនួន ១០% ធៀបនឹងឥណទានសំរាប់ចំណាយប្រេងឥន្ធនៈក្នុងឆ្នាំ ២០០៥ ដើម្បីអនុវត្តវិធានការសន្សំសំចៃថាមពលថ្នាក់ជាតិផង និង ដើម្បីត្រៀមបង្វែរចំណាយនេះ សំរាប់ចំណាយជាយថាហេតុនៃគ្រោះធម្មជាតិផង ។

ឃ- ចំពោះចំណាយជំពូកផ្សេងៗទៀត ត្រូវគ្រោងទៅតាមការចាំបាច់ និង ត្រូវស្ថិតនៅក្នុងកញ្ចប់ថវិការមដែលបានបែងចែកជូននេះដែរ ។

២០- កញ្ចប់ថវិកា គឺជាកម្មវត្ថុនៃការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។ ការពិភាក្សាថវិកានេះ គឺគ្រាន់តែជាការពិភាក្សាបែងចែកថវិកា ទៅតាមជំពូកតែប៉ុណ្ណោះ ។ ដូច្នេះ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវកសាងគម្រោងថវិកាមិនឱ្យលើសតួលេខនៃកញ្ចប់ថវិកានេះទេ ។ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងណាមួយ ដែលបានកសាងគម្រោងលើសកញ្ចប់ថវិកានេះ នឹងត្រូវកាត់ចេញនូវចំនួនដែលលើសនោះ មុននឹងចាប់ផ្តើមធ្វើការពិភាក្សា ។ ចំពោះ ក្រសួងអាទិភាពទាំងបួន ដែលមានកម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) និង កម្មវិធីសកម្មភាពជាអាទិភាព (PAP) ការពិភាក្សាលើគម្រោងចំណាយនេះ ត្រូវធ្វើឡើងដោយឡែកដោយផ្អែកលើកម្មវិធីជាក់ស្តែងទាំងនេះ ។ ចំណាយសម្រាប់កម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០១ ។ រីឯចំណាយសម្រាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០២ ។ ចំពោះកញ្ចប់ថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវបានកំណត់នៅក្នុងលិខិតដែលមានភ្ជាប់មកជាមួយនេះ ។

ឃ- ការរៀបចំ និង ការវិភាគសំណើនានា

២១- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៥ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៤ /០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៦ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម ÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា:
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត-ក្រុងមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង សាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២២- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែម ត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៣- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៤- បច្ចេកទេសវិភាគដ៏ទៃទៀតគឺ យកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។

២៥- ជាសរុប ឥណទានថវិកាចាំបាច់របស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ត្រូវតែបម្រើទៅលើ :

- គោលដៅរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ
- បណ្តាសកម្មភាពជាអាទិភាពរបស់ខ្លួន ដែលបានកំណត់ច្បាស់លាស់
- កម្មវិធីដែលត្រូវចាប់ផ្តើមអនុវត្ត
- មធ្យោបាយដំណើរការ
- និង វិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

IV- សេចក្តីសន្និដ្ឋាន

២៦- រាជរដ្ឋាភិបាលមានឆន្ទៈដាច់ខាតក្នុងការបន្តនូវកំណែទម្រង់គ្រប់វិស័យ ពិសេសគឺការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់ អនុវត្តយ៉ាងហ្មឹងម៉ាត់ និង ម៉ត់ចត់បំផុត នូវបទបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យលេខ ៦០

អនក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ប្រកាសស្តីពីការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ សម្រាប់ចំណាយក្នុងជំពូក ១១ និង ជំពូក ១៣ នៃថវិការដ្ឋ ព្រមទាំងជំពូក ៥០.០១ ចំពោះគំរោងដែលអនុវត្តដោយឯកជន ដោយលើកលែងតែចំណាយពិសេសខ្លះរបស់ព្រះបរមរាជវាំងតែប៉ុណ្ណោះ ។ ដើម្បីធានាឱ្យបាននូវភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពក្នុងការអនុវត្តន៍ចំណាយថវិកាជាតិជាពិសេស ដើម្បីជៀសវាងបញ្ហាកកស្ទះសាច់ប្រាក់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំឱ្យបានត្រឹមត្រូវនូវកម្មវិធីដេញថ្លៃជាសាធារណៈ និង ផែនការតម្រូវការសាច់ប្រាក់របស់ក្រសួង ស្ថាប័ននីមួយៗ សំរាប់ធានាទូទាត់កិច្ចសន្យាទាំងអស់នេះជាដំណាក់ៗ នៅក្នុងឆ្នាំថវិកានីមួយៗ ។

២៧- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់ នូវគម្រោងចំណូល- ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៥ ពីព្រោះការពិភាក្សា នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ខែ សីហា ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ ។ តួរលេខគំរោងចំណូល- ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

២៨- ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង ស្ថាប័ន និង មន្ទីជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៥

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"ដើម្បីមុខការ"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៨ សហវ

ប្រកាស

ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងការងារបច្ចេកទេស សំរាប់រៀបចំធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ធានារ៉ាប់រង
- បានឃើញអនុក្រឹត្យស្តីពីការធានារ៉ាប់រង លេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ដែលណែនាំការអនុវត្តន៍ច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជាលេខ ១៣២ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១
- បានឃើញលិខិតជូនដំណឹងស្តីពីការរៀបចំធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជាចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ។
- បានឃើញភាពចាំបាច់នៃការងារគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៥

សំរេច

ប្រការ ១ : បង្កើតក្រុមការងារបច្ចេកទេសដើម្បីចរចារលក់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ

១- ឯកឧត្តម	**ហង់ ជួនណារ៉ុន**	ប្រធាន
២- លោក	**ម៉ី ម៉ាន់**	អនុប្រធាន
៣- លោក	**ម៉ុញ បានកុសល**	សមាជិក
៤- លោក	**នេត មុន្នី**	សមាជិក
៥- លោក	**ម៉ូ ចន្ទ័តីរ្ទ**	សមាជិក
៦- លោក	**ទង់ សណ្តាប់**	សមាជិក
៧- លោក	**ឆាយ រតនៈ**	លេខាធិការ

ប្រការ ២ : ក្រុមការងារបច្ចេកទេសនេះមានភារកិច្ច និងតួនាទីដូចខាងក្រោមៈ

- ធ្វើការចរចារលើផ្នែកបច្ចេកទេសជាមួយក្រុមហ៊ុនទាំងឡាយណាដែលមានបំណងទិញក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិនកូ) ដោយសហការជាមួយជំនាញការ ADB ប្រសិនជាមាន
- ផ្តល់អនុសាសន៍ជូនឯកឧត្តមប្រធានគណៈកម្មាធិការឯកជនភាវូបនីយកម្ម
- ធ្វើរបាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការងារចាំបាច់ផ្សេងទៀតក្នុងការងារធ្វើឯកជនភាវូបនីយកម្ម

ប្រការ ៣ : ប្រធានក្រុមការងារមានសិទ្ធអញ្ជើញសមាជិកក្រុមការងារប្រជុំតាមការចាំបាច់របស់ខ្លួន ។

ប្រការ ៣ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥

គាត ឈន់

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  «ដើម្បីជូនជ្រាប»
- ឯកឧត្តមប្រធានគណៈកម្មាធិការឯកជនភាវូបនីយកម្ម
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧៥ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីលវើរ ស្ទេត អ៊ិនធើណេសិនណល**
SILVER STATES INTERNATIONAL Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7784/05P ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សុខ សំបូរ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥៤ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៤

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ចិន-ប៊ុន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧១ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស & អេ អ៊ិនធើប្រាយស៍ ខូ អិលធីឌី**

S & A ENTERPRISES Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2435/05E ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក STEPHEN O NYIRADY ប្រធានក្រុមប្រឹក្សាភិបាល
កញ្ញា KWANLAR TUMCHANDEE អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦E1 ផ្លូវលេខ ១១០ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ៍ណ អាហរ៍ណទំនិញ នាំចូល ឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត និង វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាកម្មនាំចូលទំនិញ និងបញ្ចេញទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ឡិក_ប៊ុង

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧៥ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ម្លិះរ័ត្ន ត្រាវែល & ធួរ**

MALIS RAT TRAVEL & TOURS Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7780/05P ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **សោ ម្លិះរ័ត្ន**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤ Eo ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រធានជីការ

ចាម ប្រសិទ្ធ

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧៤ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ណេតវើក អេស៊ា អ៊ីន**
NETWORK ASIA , INC.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2442/05E ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក JOE BYUNG CHAN

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៨១ ផ្លូវលេខ ២៧៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ [illegible] គ្រប់ប្រភេទ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន [illegible]
-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ [illegible]

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៥

ឧសសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ខ្វិត_ម៉ុខ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៣៧៦ ពណ.ឧគក

ភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សូវ៉ាន់វ៉ារី**

SUWANVAREE Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2444/05E ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោក	SUCHART KLAMCHERY	ប្រធានក្រុមប្រឹក្សាភិបាល
លោក	PASSAKORN KOOPITAKACHORN	អភិបាល
លោក	KAMOLVITH CHANRUANG	អភិបាល
លោក	SUVIT JIRUNYAKUL	អភិបាល
លោក	**សុខ ហេង**	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៧១ Eo ផ្លូវលេខ ១៩៩ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរ័ណ អាហរ័ណគ្រប់ប្រភេទ -ពិសេស នាំចេញនាំចូលប្រេងឥន្ធនៈគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ង៉ិក-ម៉ុង

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧០ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **រស្មី មានជ័យ**
	RAKSMEY MEANCHEY Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: Co. 7785/05P ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥
មានទម្រង់ជា	: សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	: លោកស្រី **ថោង សុជាតា**
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ១៦៤ EoZ ផ្លូវលេខ១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេស ទិញ លក់ ផ្គត់ផ្គង់ សំភារៈការិយាល័យគ្រប់ប្រភេទ -នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
	-សេវាបោះពុម្ពគ្រប់ប្រភេទ
	-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
	-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
	-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
	-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
	-បើកសាលារៀន
	-សេវាយកព័ត៌មានជឹងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
	-សេវាពិគ្រោះយោបល់លើផ្នែក[illegible]ពាណិជ្ជកម្ម
	-សេវាផ្សាយពាណិជ្ជកម្ម
	-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ឱ្យក_ម៉ិខ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៥២ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឯកឌីហ្សាញ គ្រុប**

EKDESIGN GROUP, INC.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7783/05P ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឯក ឫទ្ធីចំន្ទ** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ហ៊ីន គីមលីន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២២.២០០.២០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១ ផ្លូវលេខ ៣៧១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ចម_ប្រសិទ្ធ

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៤៣ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បូឌហ៊ី អ៊ិនធើប្រាយ ខូ អិលធីឌី**
BODHI ENTERPRISES Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7781/05P ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក HUGH LACHLAN MUNRO
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥ ផ្លូវលេខ ៣ ភូមិកំពង់បាយ ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ។
៥- កម្មវត្ថុអាជីវកម្ម : - ទិញ លក់ ជួល ផលិត សេវាយកកំរៃជើងសារ ដឹកជញ្ជូន និងសេវាផ្សេងៗទៀតទាក់ទងនឹងអចលនទ្រព្យ
-ប្រតិបត្តិការផ្នែក សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត និងសកម្មភាពផ្សេងៗទៀតទាក់ទងនឹងទេសចរណ៍
៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ជំនួសហត្ថលេខា
ចិត្រ_ប៊ុច

ចំលងជូន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកំពត-មន្ទីរពាណិជ្ជកម្មខេត្តកំពត "មុខការ"
- ឯកសារ -កាលប្បវត្តិ